CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៨ ថ្ងៃទី០១-៣០ ខែមេសា ឆ្នាំ២០១៥ លក់តម្លៃ ១០០០រៀល

លេខ ៨៥



## ជីវភាពគឺជាបញ្ហាប្រឈមថ្មីសម្រាប់ពលរដ្ឋដែលផ្ទុកមេរោគអេដស៍នៅក្នុងតួមិរការ

## សេចក្តីជូនដំណឹង

គណៈកម្មការសម្រាប់កិច្ចការមរណសាក្សីនៅកម្ពុជា សូមជម្រាបដល់បងប្អូនគ្រីស្តបរិស័ទទាំងអស់ ឲ្យបានជ្រាបថា បច្ចុប្បន្នគណៈកម្មការយើងខ្ញុំកំពុងធ្វើ និង ចងក្រងសំណុំឯកសារអំពីមរណសាក្សី នៃព្រះសហគមន៍កាតូលិក។ សូមបងប្អូនសហការផ្តល់ជាព័ត៌មានមកកាន់ ៖ **លោក រឿង ឆ័ត្រសិរី** ( Fr. RoeungChatsirey )។

Tel: 077 800 211 / 096 34 22 144

អ៊ីម៉ែល ៖ martyrscambodia@gmail.com | ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ

យុវជនចាប់អារម្មណ៍ទៅលេងនៅតំបន់អារ៉ែងនៃខេត្តកោះកុងកាន់តែច្រើនឡើងៗ។ តំបន់អារ៉ែងអាចក្លាយជាតំបន់ទេសចរណ៍ថ្មីមួយ ព្រោះនៅតំបន់នោះសំបូរដោយរមណីយដ្ឋានធម្មជាតិ និងសត្វព្រៃ។














Radio Veritas Asia
Crossing Borders, Sharing Christ

**វិទ្យុវ៉ារីតាស់អាស៊ី ( RVA )ផ្សាយតាមរលកធាតុអាកាសខ្លី ( SW )**
**ភាសាខ្មែររយៈពេល ៣០ នាទីរាល់ថ្ងៃ :**

ពីម៉ោង៥:០០-៥:៣០នាទីល្ងាច តាមរលកធាតុអាកាសខ្លី ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

ស្តាប់វិទ្យុវ៉ារីតាស់អាស៊ី ( RVA ) លោកអ្នកនឹងទទួលបានចំណេះដឹងទូទៅជាច្រើនទាក់ទងនឹង ជីវិតរស់នៅប្រចាំថ្ងៃ សង្គម និងព័ត៌មាននានាពីព្រះសហគមន៍កាតូលិកកម្ពុជា។

**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ

**Tel/Fax** : (855) 23 224 120

**Email** : csccambodia@gmail.com / **Website** : www.catholiccambodia.org

**ចាងហ្វាង : លោក លី សុវណ្ណា**

Licence ៣៧០ ពម.ប្រក./ ២៤-មិថុនា-២០១០

# រីករាយបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ



លោក **លី សុវណ្ណា**
ចាងហ្វាងកាសែតអ្នកនាំសារ

*"អាលេលូយ៉ា!"* សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់! ព្រះជាម្ចាស់ពិតជាប្រោសព្រះយេស៊ូគ្រីស្ត ឲ្យមានព្រះជន្មឡើងវិញ ពីចំណោមមនុស្សស្លាប់ពិតមែន។ នេះជាជំនឿរបស់យើងជាគ្រីស្តបរិស័ទ ព្រះគ្រីស្តបានសោយទិវង្គត និង មានព្រះជន្មរស់ឡើងវិញ។

នៅក្នុងពិធីបុណ្យ ដ៏ឱឡារិកនេះ *អ្នកនាំសារ* ក៏សូមចូលរួមអបអរសាទរចំពោះអស់បងប្អូន ទាំងប្រុសទាំងស្រី កុមារា កុមារី ប្រមាណជាង២០០ នាក់ ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹក ក្នុងឱកាសបុណ្យព្រះយេស៊ូមានព្រះជនរស់ឡើងវិញនេះ។ បងប្អូនទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ។ជីវិតថ្មីដែលបងប្អូនទទួលគឺជាមរតក ដែលព្រះជាម្ចាស់ប្រទានដល់អស់បងប្អូន ។ យើងជឿថា មនុស្សទាំងអស់ជាបុត្រធីតារបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់នឹងត្រាស់ហៅបងប្អូន ដែលមិនទាន់ទទួលស្គាល់ឋានៈរបស់ខ្លួន តាមឈ្មោះរបស់គេម្នាក់ៗ។

យើងសូមអធិដ្ឋាន សម្រាប់បងប្អូន ដែលទើបទទួលជីវិតថ្មី សូមព្រះជាម្ចាស់ប្រទានកម្លាំងកាយ កម្លាំងចិត្ត និងជំនឿបន្ថែមទៀត ដើម្បីឲ្យគេអាចរស់នៅ បានសមប្រកបជាបុត្រធីតារបស់ព្រះអង្គ ដោយរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូក្នុងលោកនេះ។ សូមឲ្យបងប្អូនអាចធ្វើជាចលករ នៃការកសាងសន្តិភាព សេចក្តីស្រឡាញ់ចេះកសាងយុត្តិធម៌ក្នុងសង្គមបច្ចុប្បន្ន ។ ចេះយកចិត្តទុកដាក់ជាមួយអស់អ្នកដែលសង្គមបោះបង់ចោល អ្នកជំងឺ ក្រីក្រ ទុគ៌តជន ។ សូមឲ្យបងប្អូនទៅជាពន្លឺមួយនៅក្នុងសង្គម ពន្លឺនៃការសន្ទនា ពន្លឺនៃការស្រឡាញ់ ពន្លឺនៃយុត្តិធម៌ ពន្លឺនៃការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ចេះលើកទឹកចិត្តអ្នកក្រីក្រ អ្នកទន់ខ្សោយខាងផ្លូវវិញ្ញាណ ឲ្យចូលរួមក្នុងការអភិវឌ្ឍសង្គមកម្ពុជា។ ចេះនាំគេឲ្យលះបង់ចោលចិត្តលោភលន់ ចង់មានចង់បានហួសហេតុ។ល។

ជាមួយគ្នានេះ យើងខ្ញុំក៏មិនភ្លេចអស់បងប្អូន ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកកន្លងទៅថ្មីៗ និងយូរមកហើយដែរ សូមព្រះជាម្ចាស់ពង្រឹងជំនឿបងប្អូន ឲ្យបន្តបេសកកម្មរបស់ខ្លួន សមប្រកបតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ផង...។

ទាំងបងប្អូនចាស់ ទាំងបងប្អូនថ្មី យើងសុទ្ធតែបានទទួល ព្រះវិញ្ញាណតែមួយជំនឿតែមួយ ហើយយើងមានព្រះបិតាតែមួយដែរ ផ្នែកជីវិតផ្លូវវិញ្ញាណ។

សូមយើងចែករំលែក នូវបទពិសោធន៍ អំពីអំណរសប្បាយ នៃបុណ្យចម្លងដល់អស់បងប្អូន ដែលនៅជុំវិញយើង។ គឺជាបទពិសោធន៍នៃជីវិតថ្មី ដែលបងប្អូនបានទទួលរួមជាមួយព្រះយេស៊ូ។ធ្វើសក្ខីភាពដែលបញ្ជាក់ថា "ព្រះយេស៊ូជាផ្លូវ ព្រះយេស៊ូជាសេចក្តីពិត និង ព្រះយេស៊ូជាជីវិត" ៕



# ការបណ្តុះផ្សិតរបរដែលគ្រប់គ្នាមិនអាចមើលរំលងបាន



ផ្សិតចំបើងដែលកសិករបានបណ្តុះនៅតាមកសិដ្ឋាន ។រូបថតៈ សុន ម៉ៅ

ការបណ្តុះផ្សិតជាមុខរបរដ៏សាមញ្ញមួយ ប៉ុន្តែជាតុពិត គឺវាជារបរដែលគ្រប់គ្នា មិនអាចនឹងមើលរំលងបាន ហើយប្រភពប្រាក់ចំណូលវិញនោះក៏មិនជាអន់ឡើយ ប្រសិនបើតាំងចិត្ត និងដាក់កាយ ខំប្រឹងអនុវត្តរបរនេះ។

សព្វថ្ងៃនេះ មានកសិករសាមញ្ញជន មន្ត្រីរាជការ ព្រមទាំងតារាមួយចំនួន បានបណ្តាក់ទុនរៀបចំ ជាកន្លែង បណ្តុះផ្សិតឡើងព្រោងព្រាត តាមធនធាន តាមផ្ទៃដី តាមសមត្ថភាព នៃទុនរបស់ពួកគេ ហើយផ្សិតដែលពួកគេ អាចមានសមត្ថភាពបណ្តុះនោះ គឺមានផ្សិតអំបោះ និងផ្សិតចំបើង ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ផ្សិតនៅតែជាទំនិញដ៏ពេញនិយមមួយប្រភេទ សម្រាប់ប្រជាពលរដ្ឋនៅលើទីផ្សារ ។

លោកស្រី សេង ចាន់សុផា ជាអ្នកលក់ផ្សិតមួយរូបបានអះអាងថា សព្វថ្ងៃនេះ តំរូវការផ្សិតមានប៉ុន្មានក៏លោកស្រីអាចមាន ម៉ូយសម្រាប់យកដែរ ប៉ុន្តែសំខាន់ គឺពិបាកដើរទិញ និងមិនមានផ្សិតសម្រាប់ផ្តល់ឲ្យ ។

លោកស្រីបានអះអាងថា ផ្សិតដែលលោកស្រីដើរប្រមូលទិញ គឺមានផ្សិតចំបើង និង ផ្សិតអំបោះនេះដោយលោកស្រីដើរប្រមូលទិញខ្លះ ៣០ទៅ ៤០ គ.ក ខ្លះ ១០ ទៅ ២០ នៅគ្រប់ទីកន្លែង សរុបទៅ គឺបានត្រឹមតែ ៥០ ទៅ ៧០ គ.ក នេះគឺអស់ហើយ យកមកបោះបន្តឲ្យម៉ូយ នៅតាមទីផ្សារ និង កន្លែងលក់ស៊ុបមួយចំនួន ។

លោកស្រី បានបញ្ជាក់ថា "ផ្សិតមានទីផ្សារល្អណាស់ ហើយតំរូវការគឺខ្ពស់ ប៉ុន្តែពេលនេះអ្នកដាំ គឺមានតិចពិបាកដើរប្រមូលទិញបន្តិច "។

ផ្សិតត្រូវបានគេដឹងថា គឺជាអាហារប្រពៃណីមួយ របស់ប្រជាពលរដ្ឋកម្ពុជានៅតាមស្រុកនៅតាមភូមិ ដោយពីមុននេះភាគច្រើន អាហារចម្អិនពីផ្សិតនេះច្រើនមាននៅដើមរដូវវស្សា ពេល គឺ នៅពេលដែលធ្លាក់ភ្លៀងដើមឆ្នាំបង្អុរចុះមកស្រោចស្រប់ដំបូង ។ ផ្សិតដែលប្រជាពលរដ្ឋបេះយកមកទទួលទាននោះ គឺមានជាច្រើនប្រភេទដូចជា ផ្សិតចំបើង ផ្សិតក្ងោក ផ្សិតទន្សោង... ដោយផ្សិតទាំងនោះត្រូវបានប្រជាពលរដ្ឋប្រើប្រាស់វាសម្រាប់ចម្អិនជា ឆា ស្ងោរ ប្រហើរ ... ប៉ុន្តែនៅពេលបច្ចុប្បន្ននេះវិញ មានផ្សិតមួយចំនួន ត្រូវបានប្រជាពលរដ្ឋកម្ពុជាចេះបណ្តុះ ជាពិសេសគឺផ្សិតចំបើង និង ផ្សិតអំបោះ។

លោក ចេត រចនាប្រជាពលរដ្ឋនៅភ្នំពេញមួយរូបបានអះអាងថា សព្វថ្ងៃនេះលោកក៏មានកសិដ្ឋានបណ្តុះផ្សិតមួយកន្លែងដែរ នៅខេត្តកំពង់ឆ្នាំង ។

លោកបានអះអាងថា ជាមួយនឹងផ្ទៃដីប្រមាណជាកន្លះហិចតា លោកបាន ចំណាយទុនតែ បន្តិចបន្តួចប៉ុណ្ណោះ ប៉ុន្តែបានទទួលផលពីរបរបណ្តុះផ្សិតនេះវិលជុំ ហើយអាចទទួលបានចំណូលនេះរាល់ថ្ងៃដោយមួយថ្ងៃ ពី ៣០ ទៅ ៤០ ម៉ឺនរៀលក៏មាន ។

លោកបានអះអាងថា បណ្តុះផ្សិតនេះមិនត្រូវការអ្វីច្រើនទេ សំខាន់ឲ្យតែមានដី ហើយមានលុយតិចតួច ធ្វើរោង តែមិនចាំបាច់ដល់ទៅធ្វើរោងសង្កសីអ្វីនោះទេ គឺប្រក់តែស្លឹកហើយទិញចង់ ទិញមេ ទិញ អាច់រណាជាការស្រេច។

លោកបានបន្តទៀតថា "របរនេះមិនឈឺក្បាលអ្វីទាំងអស់ គឺចំណាយពេលត្រឹមតែពីរខែដំបូងទេ បន្ទាប់មកគឺប្រមូលលុយរាល់ថ្ងៃ"។ លោកបានបញ្ជាក់ទៀតថា "របរនេះចំណាយតែម្តង គឺកាត់យកលុយរាល់ថ្ងៃ ម្តងអាចង់នេះ ម្តងអាចង់នោះ"។

លោកបានបន្តទៀតថា អ្នកខ្លះចំណាយទុនរាប់ពាន់ដុល្លារ ធ្វើនេះ ធ្វើនោះ តែប្រមូលប្រាក់ចំណូលមកមិនស្មើនឹងផ្សិតនេះទេ ដោយសារតែការដាំផ្សិតនេះ មិនប្រើប្រាស់របស់ធំដុំនោះទេ គឺត្រូវការត្រឹមតែបច្ចេកទេសដែលរៀនសូត្រត្រឹមតែ បីខែ ហើយអ្នកខ្លះ គេរៀនត្រឹមតែ មួយសប្តាហ៍ គឺគេចេះបាត់ទៅហើយ ។

លោកបានបញ្ជាក់ថា "របរនេះវាមិនល្អមើលទេ គឺជារបរអ្នកស្រែ ប៉ុន្តែប្រាក់ចំណូល គឺបានសមរម្យគ្រាន់នឹងទប់ថ្លៃជីវភាព"។

ការបណ្តុះផ្សិតនេះ មិនត្រូវការធនធានអ្វីច្រើនធំដុំនោះទេ គឺគេអាចកែច្នៃចេញមកពីសំរាម កំទិចកំទីតែជុំវិញភូមិ និង កន្លែងបណ្តុះនេះតែប៉ុណ្ណោះ ពោលគឺមានដូចជា មានរោងមួយ ដែលមិនចាំបាច់សង់អ្វីមាំទាំពេកទេ បើសិនជាខ្វះខាតធនធាន ប៉ុន្តែសំខាន់ គឺកន្លែងនោះ មានខ្យល់អាកាសល្អ ឆ្ងាយពីកន្លែងចិញ្ចឹមសត្វ ដោយឡែកសម្រាប់វត្ថុធាតុដើមយកមកផលិតវិញនោះ គឺកំបោរ កន្ទក់ចុងអង្ករ ចំបើង គល់ជញ្ជ្រាំង ឬ អាចជាកាកអំពៅ កំប្លោកក្រៀម ជួនកាលគឺមានដើមចេកហាន់ ហើយហាលឲ្យក្រៀម សំបកសណ្តែកបាយ ស្នូលគរ សំបកដំឡូងមី ស្នូលពោត និង ដីកំប៉ុស្ត កំទិច អាចម៍រណា ។ល។

លោកបានបន្តទៀតថា ក្រៅពីរបរបណ្តុះផ្សិតនេះ របរចិញ្ចឹមសត្វ និងដាំដំណាំហូបផ្លែ ដែលមានលក្ខណៈបច្ចេកទេសក៏ជាចំណុចមួយ ដែលកសិករទាំងឡាយគួរ តែ យកចិត្តទុកដាក់ផងដែរ។

លោកបានបន្តទៀតថា នៅពេលនេះរបរផលិតកម្ម កសិកម្មនេះ គឺជារបរមួយ ដែលកំពុងតែមានតំរូវការ ដោយសារតែ អ្នកត្រូវការហូបមានច្រើន ហើយអ្នកដែលផ្គត់ផ្គង់នៅមានតិច។

លោកបានបន្តទៀតថា ដូចផ្សិតជាដើម សម័យមុន គឺគ្មានពលរដ្ឋកម្ពុជាណាចេះបណ្តុះទេ គឺមានតែបេះតាមធម្មជាតិប៉ុន្តែពេលនេះដោយសារ បម្រែបម្រួលអាកាសធាតុបរិស្ថាន និង សកម្មភាពរបស់មនុស្ស មានផ្សិតឯណាមកដុះឲ្យបេះទៀត គឺមានតែបណ្តុះ។

លោកបានបញ្ជាក់ថា "ផ្សិតធម្មជាតិឯណាទៅដុះទាន់ បើមាត់មនុស្សច្រើនយ៉ាងនេះនោះ"។

លោកក៏បានលើកទឹកចិត្តកសិករឲ្យព្យាយាមស្វែងរកចំណេះដឹងពីរបរកសិកម្មនេះ នៅតាមកម្មវិធីបណ្តុះបណ្តាលខ្លីៗ ដែលអង្គការ និងសមាគមនានាគេបានបង្រៀន៕

**ដោយអរិយបុត្រ**

# អាជ្ញាធរកម្ពុជាកំពុងតម្រង់ទិសយុវជន ប៉ុន្តែទិសដែលតម្រង់ហាក់ដូចជាស្រពេចស្រពិល



*សិស្សប្រឡងមធ្យមសិក្សាទុតិយភូមិមើលលទ្ធិផលប្រឡងឆ្នាំ២០១៤។ រូបថតៈ លីហៀង*

អាជ្ញាធរកម្ពុជា នាពេលបច្ចុប្បន្ននេះ ជាពិសេសគឺក្រសួងអប់រំ យុវជន និង កីឡា កំពុងតែអនុវត្តការតម្រង់ទិសរបស់យុវជនប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ទិសដែលក្រសួងបានតម្រង់ត្រូវបានយុវជន និងសាស្ត្រាចារ្យមួយចំនួនអះអាងថា គឺហាក់ដូចជាស្រពិចស្រពិលសម្រាប់ពួកគេ ។

ការតម្រង់ទិសនេះ ត្រូវបានក្រសួងអប់រំយុវជន និងកីឡា គឺកំពុងតែដាក់ចេញ ដើម្បីអនុវត្តកំណែទម្រង់ការអប់រំនៅកម្ពុជា តាំងពីមុនឧត្តមរហូតដល់ក្រោយឧត្តមសិក្សាដើម្បីឲ្យឆ្លើយតបនឹងទីផ្សារការងារ និង តំរូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច ដោយព្យាយាមពន្យល់ណែនាំមាគ៌ា ឲ្យសិស្សានុសិស្សងាកមកសិក្សា លើកផ្នែកជំនាញបច្ចេកទេស ខណៈដែលបច្ចុប្បន្ននេះយុវសិស្សនៅកម្ពុជាគឺភាគច្រើនផ្តោតតែនៅលើមុខវិជ្ជា ក្នុងវិស័យធុរកិច្ចផ្សេងៗ ដែលមានដូចជា ជំនាញគ្រប់គ្រង គណនេយ្យ ធនាគារ និងហិរញ្ញវត្ថុ ទីផ្សារ ទេសចរណ៍ ច្បាប់ពាណិជ្ជកម្ម។ល។

ជុំវិញបញ្ហានេះ សាស្ត្រាចារ្យវិទ្យាល័យទួលទំពូងមួយរូប ដែលសុំមិនបញ្ចេញឈ្មោះបានឲ្យដឹងថា ក្រោយពីមានការណែនាំ ពីសំណាក់នាយកសាលា ដែលលោកបានទទួលការណែនាំ ពីថ្នាក់ក្រសួងជាបន្ត លោកគឺអនុវត្តតាមស្មារតីណែនាំនេះ គឺបានចូលរួម នៅក្នុងការតម្រង់ទិសដល់យុវសិស្សទាំងឡាយ ពោលគឺជំរុញនឹងធ្វើឲ្យពួកគេ បង្វែរការគិតអំពីវិជ្ជាធុរកិច្ច មកការងារផ្នែកបច្ចេកទេស ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការសម្រេចគឺជាសិទ្ធិរបស់ពួកគេ។

លោកបានបញ្ជាក់ថា "ការជ្រើសរើសមុខជំនាញសិក្សា នៅថ្នាក់ឧត្តមសិក្សា គឺជាសិទ្ធិរបស់សិស្សម្នាក់ៗនិងគ្រួសាររបស់គេ ចំណែកខ្ញុំ បានត្រឹមតែតម្រង់តែប៉ុណ្ណោះ"។

លោកសាស្ត្រាចារ្យ បានបន្តទៀតថា មកដល់ពេលនេះ អ្វីដែលលោកបានតម្រង់ប្រហែលជាបាន ត្រឹមតែតម្រង់នោះទេ ពីព្រោះការតម្រង់នេះប្រហែលជាមិនជោគជ័យ នៅពេលនេះទេ ដោយសារតែយុវសិស្ស ហាក់ដូចជា មុតស្រួចទៅលើធុរកិច្ចនេះហើយ។

លោកបានបញ្ជាក់ថា "នៅពេលបច្ចុប្បន្ននេះតម្រង់បានត្រឹមតែតម្រង់ប៉ុណ្ណោះ ខណៈដែលគំនិត និង ទិសដៅសិស្សត្រូវបានសង្គមសម្រួចការគិតធុរកិច្ចនេះ តាំងតែពីណា ពីណីមក ដូច្នេះបើចង់ជោគជ័យ គឺមានតែប្រើពេលវេលា"។

លោកបានបន្តទៀតថា "ខ្ញុំគិតថា មិនជោគជ័យទេ ជំនាន់នេះហើយបើចង់ជោគជ័យ គឺត្រូវតែបញ្ជ្រាបតាំងពីកុមារមក"។

ឱ សុវណ្ណរ័ត្ន យុវសិស្ស ដែលកំពុងសិក្សា ថ្នាក់ទី១០ នៅវិទ្យាល័យបាក់ទូក បានអះអាងថា នៅក្នុងថ្នាក់សិក្សានៅពេលនេះ គឺលោកគ្រូអ្នកគ្រូ គាត់ជំរុញឲ្យរៀនបច្ចេកទេស តែខ្ញុំប្រហែលជាមិនចង់ទេ គឺខ្ញុំចង់រៀនធនាគារវិញ ។

ជេត សម្បត្តិ យុវសិស្ស ថ្នាក់ទី១២ មួយរូបផ្សេងទៀតក៏អះអាងស្រដៀងនេះផងដែរ ដោយអះអាងថា បើសិនជាខ្ញុំមានសមត្ថភាព និងមានសំណាងប្រឡងជាប់នៅក្នុងឆ្នាំនេះមែន ខ្ញុំចង់រៀនផ្នែកពាណិជ្ជកម្ម និង វិនិយោគ បើមាន ប៉ុន្តែបើប្រឡងធ្លាក់វិញ គឺរៀនបរិញ្ញាប័ត្ររង ពីរឆ្នាំសិន ចាំរៀនបន្តបរិញ្ញប័ត្រជំនាញដែលខ្ញុំ ស្រឡាញ់វិញ ។

សម្បត្តិ បានអះអាងថា មិនចង់រៀនបច្ចេកទេសនោះទេ ដោយសារតែការងារនេះ គឺជាការងារមួយដែលហត់ហើយបរិយាកាសការងារ ក៏គ្រោះថ្នាក់ដោយភាគច្រើនគឺជំនាញធ្វើការតែនៅការដ្ឋាន និងនៅតាមរោងចក្រឧស្សាហកម្មតែប៉ុណ្ណោះ ។

ជុំវិញបញ្ហានេះលោកសាស្ត្រាចារ្យខាងលើ បានមានប្រសាសន៍ថា ការតម្រែតម្រង់នេះ គឺមិនមែនមានតែគ្រូទេ ដែលអាចជួយបាននោះ គឺត្រូវមានការយល់ដឹងតាំងពីគ្រួសារ ហើយព្យាយាមបណ្តុះគំនិត និង តម្រង់ជីវិត និងការគិត របស់សិស្សតាំងពីនៅកុមារភាពហើយត្រូវការពេលវេលាមួយសមស្រប។

លោកបានបន្តទៀតថា នៅពេលបច្ចុប្បន្ននេះ ការតម្រែតម្រង់ទិសដៅនេះ គឺបានត្រឹមតែមាត់ទេ ប៉ុន្តែឧទាហរណ៍ បើសិស្សចាប់អារម្មណ៍វិញនោះ ក៏សិស្សមិនដឹងជាទៅរៀនជំនាញនេះនៅទីណានោះដែរ ដោយសារតែពេលនេះ នៅក្នុងចំណោមសាកលវិទ្យាល័យ វិទ្យាស្ថាន ដែលបើកព្រោងព្រាត នៅក្នុងប្រទេស មានប៉ុន្មាន ដែលជាស្ថាប័នអប់រំបច្ចេកទេស គឺភាគច្រើនសុទ្ធតែផ្នែកធុរកិច្ច។

លោកបានបញ្ជាក់ថា "មកដល់ពេលនេះបើសិស្សគាត់ចាប់អារម្មណ៍ចង់រៀនបច្ចេកទេសនេះ ហើយសួរខ្ញុំថា ទៅរៀននៅទីណា ខ្ញុំក៏ពិបាកនឹងប្រាប់គាត់ដែរ ដោយសារតែខ្ញុំមិនសូវជាស្គាល់ច្រើន"។

រហូតមកដល់ពេលនេះ នៅកម្ពុជាត្រូវបានគេដឹងថា មានស្ថាប័នឧត្តមសិក្សា ដែលមានដូចជា សាកលវិទ្យាល័យ ឬជាវិទ្យាស្ថាននោះ គឺប្រមាណជាជាង ១០០ ស្ថាប័ន ទាំងរដ្ឋ និងឯកជន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងចំណោមស្ថាប័នទាំងនោះ បើនិយាយអំពីស្ថាប័ន ដែលបណ្តុះបណ្តាលជំនាញ ផ្នែកបច្ចេកទេស គឺនៅមានកំរិត ។

សម្រាប់ការសិក្សាកម្រិតបច្ចេកទេសវិញ គឺមានតួរលេខស្ថាប័ន គឺមានច្រើន ប៉ុន្តែជំនាញពិតប្រាកដនៅមានកង្វះខាត ហើយបណ្តុះបណ្តាល គឺខុសជំនាញ៕

**ដោយអរិយបុត្រ**

# លោកឆ័ត្រសិរីៈ អត្តសញ្ញាលើកលែងទោស គឺការសោកស្ដាយអំពើបាប និងមិនចង់ប្រព្រឹត្តម្ដងទៀតពេញមួយជីវិត



លោកបូជាចារ្យ រឿង ឆ័ត្រសិរី។រូបថតៈ Photo supply

លោកបូជាចារ្យ រឿង ឆ័ត្រសិរី បានមានប្រសាសន៍ឲ្យដឹងថា អគ្គសសញ្ញាលើកលែងទោស ឬគ្រីស្តបរិស័ទកាតូលិកតែងហៅថា ពិធីស្រាយបាប ដែល នៅក្នុងគោលលទ្ធិព្រះសហគមន៍កាតូលិកគេហៅថា ការកែប្រែចិត្តគំនិត ឬការសោកស្ដាយនឹងអំពើបាបរបស់ខ្លួន (ccc1423)។ ក្នុងន័យនេះ បានសេចក្តីថា អ្នកដែលប្រព្រឹត្តអំពើបាប មិនចង់ប្រព្រឹត្តអំពើខុសនោះម្តងទៀតឡើយ ពេញមួយជីវិត ដោយការខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់ខ្លួន តែបើអត់មានការខិតខំនេះទេ ការស្រាយបាប គឺអត់បានការទាល់តែសោះ។ លោកបូជាចារ្យបានសង្កត់ធ្ងន់ថា អ្នកទៅសារភាពបាប គឺមានបំណងកែតម្រូវខ្លួនវិញពិតមែន។

លោកបានបន្តថា ក្នុងគម្ពីរ ព្រះបន្ទូលព្រះយេស៊ូ បានធ្វើឲ្យមនុស្សខ្វាក់ពីកំណើត និងអ្នកមានជំងឺផ្សេងៗ ដែលនៅជំនាន់នោះគេជឿថា ពួកគាត់ខ្វាក់ ឬមានជំងឺមកពីអំពើបាបរបស់គាត់ ប៉ុន្តែចំពោះព្រះយេស៊ូ ព្រះអង្គបានធ្វើឲ្យអ្នកខ្វាក់ និង អ្នកជំងឺជាសះស្បើយ។អត្ថន័យនៃការព្យាបាលនេះ គឺមិនត្រឹមតែជួយខាងរាងកាយទេ តែជួយខាងវិញ្ញាណផង។ ប៉ុន្តែលក្ខខ័ណ្ឌ សម្រាប់ការព្យាបាលនោះ គឺ "ជំនឿ" និងការជៀសវាងកុំធ្វើបាបទៀតដូចព្រះអង្គ មានព្រះបន្ទូលជាមួយស្ត្រី ដែលត្រូវគេគប់ដុំថ្មជាដើម។ ព្រះយេស៊ូចង់ឲ្យគេកែប្រែ។ ព្រះអង្គចង់បង្ហាញ អំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ចំពោះមនុស្សលោក ដូច្នេះ លោកបូជាចារ្យដើរតួពីរ ដូចព្រះអង្គ គឺជាគ្រូពេទ្យផង និង ជាចៅក្រមផង។ (មាត្រា៩៧៨)

តាមប្រសាសន៍ របស់លោកបូជាចារ្យរូបនេះបានប្រាប់ទៀតថា អគ្គសញ្ញាលើកលែងទោស អាចធ្វើបានពីររបៀបគឺរបៀបធម្មតា(ផ្ទាល់ខ្លួនជាមួយលោកបូជាចារ្យ) និងធ្វើរួមគ្នា ហើយត្រូវធ្វើនៅក្នុងបរិវេណ ព្រះវិហារ ប្រសិនបើមានការចាំបាច់ខ្លាំងអាចធ្វើនៅខាងក្រៅក៏បានដែរ (មាត្រា៩៦៤)។ការធ្វើអគ្គសញ្ញាស្រាយបាបរួម គឺកម្រមានណាស់ លុះត្រាតែមានអាសន្នដូចជាមានសង្គ្រាមគ្រោះថ្នាក់ណាមួយ...។ ប៉ុន្តែក្រោយពេលចប់គ្រាអាសន្ន អស់អ្នកដែលបានស្រាយបាបរួម ដែលរស់រានមានជីវិតអាចមកស្រាយបាប ផ្ទាល់ខ្លួនពេលក្រោយ។ ឧទាហរណ៍ដូចពេលដែលលោកអភិបាល ទេពអ៊ីម សុថា បានធ្វើដល់គ្រីស្តបរិស័ទនៅបាត់ដំបង មុនពេលខ្មែរក្រហមវាយយក ក្រុងបាត់ដំបង។ លោកអភិបាលបានធ្វើអគ្គសញ្ញាស្រាយបាបរួមគ្នា ដល់គ្រីស្តបរិស័ទ និងអស់គ្រីស្តបរិស័ទដែលគ្មានវត្តមាន នៅក្នុងព្រះវិហារនោះដែរ។ លោក ឆ័ត្រសិរី បន្ថែមថា ចំណែកឯការស្រាយបាបផ្ទាល់ខ្លួន គឺត្រូវធ្វើឡើងម្នាក់ៗផ្ទាល់ខ្លួន ជាមួយលោកបូជាចារ្យ។ ហើយភាគច្រើនគ្រីស្តបរិស័ទកាតូលិក ធ្វើនៅក្នុងព្រះវិហារមុនពេលថ្វាយអភិបូជា ព្រោះពួកគាត់គិតថា ដើម្បីឲ្យមានភាពសមរម្យក្នុងការទទួល ព្រះកាយព្រះយេស៊ូ។ ប៉ុន្តែពួកគាត់ ក៏អាចធ្វើបានដែរក្រោយពេលអភិបូជា ត្រូវបានបញ្ចប់។

លោកបូជាចារ្យ ឆ័ត្រសិរី ឲ្យដឹងទៀតថា អំពើបាបមានពីរប្រភេទ គឺអំពើបាបស្រាល និងអំពើបាបធ្ងន់។ ប៉ុន្តែអំពើបាបធ្ងន់ ឬស្រាលយើងត្រូវមើលលើឆន្ទៈ និងចេតនារួមទាំងបរិបទរបស់ទង្វើបាបនោះផងដែរ។ អំពើបាបធ្ងន់នោះរួមមាន ការសម្លាប់មនុស្ស អំពើផិតក្បត់(ប្តីប្រពន្ធ) ការបដិសេធមិនទទួលស្គាល់ជំនឿ ជាដើម...។អំពើបាបធ្ងន់ទាំងនេះលោកបូជាចារ្យធម្មតាមិនអាចធ្វើអគ្គសញ្ញាជូនអ្នកប្រព្រឹត្តបានទេ លុះត្រាតែលោកបូជាចារ្យរូបនោះ ទទួលការអនុញ្ញាតពីលោកអភិបាល ព្រោះមានបាបមួយចំនួនត្រូវរក្សាទុក សម្រាប់លោកអភិបាលតែប៉ុណ្ណោះ ដែលមានសិទ្ធិលើកលែងទោសឲ្យបាន។ ដូចនៅក្នុងភូមិភាគភ្នំពេញ លោកអភិបាលបានផ្តល់សិទ្ធិ ដល់លោកបូជាចារ្យ ដែលទទួលខុសត្រូវមណ្ឌលសកម្មភាពនៅតាមតំបន់ ឲ្យអាចធ្វើអគ្គសញ្ញា លើកលែងទោស ចំពោះអំពើបាបធ្ងន់ឲ្យដល់គ្រីស្តបរិស័ទ ដោយផ្ទាល់បាន។ រីឯក្រុមគ្រួសារបព្វជិត (អ្នកបួស) ដែលទទួលការតែងតាំងជាបូជាចារ្យ គឺពួកគាត់មានសិទ្ធិធ្វើអគ្គសញ្ញាលើកលែងទោស បានដូចបូជាចារ្យ ដែលមានការតែងតាំងដែរ ប៉ុន្តែលោក មានសិទ្ធិធ្វើតាមការអនុញ្ញាតរបស់អ្នកមានអំណាច របស់គាត់។

លោកបូជាចារ្យ ឆ័ត្រសិរី បានមានប្រសាសន៍បញ្ជាក់ថា អគ្គសញ្ញាលើកលែងទោសមិនអាចធ្វើទៅបាន តាមរយៈប្រព័ន្ធបច្ចេកទេសសម័យទំនើបបានទេ ដូចជាទូរស័ព្ទ ប្រព័ន្ធអ៊ីនធឺណេត ឬប្រព័ន្ធសង្គមហ្វេសបុក ជាដើម។ល។ ពីព្រោះលោកបូជាចារ្យមិនអាចដឹងថាគ្រីស្តបរិស័ទម្នាក់នោះត្រូវបានគេបង្ខំឲ្យធ្វើអគ្គសញ្ញាស្រាយបាបឬអត់។ លោកបានសង្កត់ធ្ងន់ថា អគ្គសញ្ញាស្រាយបាបគឺមិនអាចមានប្រសិទ្ធភាពនោះទេ ប្រសិនបើគាត់គ្មានឆន្ទៈក្នុងការធ្វើវា។

នៅក្នុងព្រះសហគមន៍ កាតូលិក អគ្គសញ្ញាលើកលែងទោស ត្រូវបានស្នើសុំឲ្យគ្រីស្តបរិស័ទ កាតូលិកធ្វើដោយផ្ទាល់ខ្លួនជាមួយបូជាចារ្យ ជាញឹកញាប់ទោះបីច្បាប់បានសំណូមពរឲ្យបាន យ៉ាងតិចណាស់មួយដងក្នុងមួយឆ្នាំក៏ដោយ ជាពិសេសនៅក្នុងឱកាសបុណ្យធំៗ ដូចជាបុណ្យព្រះយេស៊ូប្រសូត និងបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញដ៏រុងរឿង (បុណ្យចម្លង)៕


## ដំណឹងជ្រើសរើសបុគ្គលិក

| | | |
|---|---|---|
| តួនាទី | : | នាយក/នាយិកាសាលាបឋមសិក្សា(ចំនួន ១នាក់) |
| ចំនួនម៉ោងធ្វើការ | : | ៤០ម៉ោងក្នុង១សប្តាហ៍ (ពេញពេល) ឬ២០ម៉ោងក្នុង១សប្តាហ៍ (ពាក់កណ្តាលពេល) |
| ប្រាក់បៀវត្សន៍ | : | ២៧០ដុល្លារ(ពេញពេល) , ១០០ដុល្លារ(ពាក់កណ្តាលពលេ) |
| ទីតាំង | : | ខេត្តបន្ទាយមានជ័យ |

ប្រសិនបើលោកគ្រូ អ្នកគ្រូមានចំណាប់អារម្មណ៍ សូមផ្ញើCVទៅកាន់ការិយាល័យសាលាដេស៊ីតសន្តសាវីយ៉េដោយផ្ទាល់ ដែលមានអាសយដ្ឋាននៅផ្លូវលេខ ៤ ភូមិសុភី ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឬផ្ញើជូនប្រធានគម្រោងកញ្ញា ផុន សុណៃតាមរយៈអ៊ីម៉ែលនិងលេខទូរស័ព្ទដូចខាងលើៈ

អ៊ីម៉ែលៈ
sonai.phon79@gmail.com
ទូរស័ព្ទលេខៈ 012 276 220, 098 940 497, 097 611 3197

# ចេញពីគ្រួសារក្រីក្រតែអាចតស៊ូរៀនដល់បណ្ឌិតត្រឹមវ័យជាង ៣០ ឆ្នាំតែប៉ុណ្ណោះ



*លោក សម រ៉ានី នាយកវិទ្យាស្ថានភាសាបរទេសនៅសាកលវិទ្យាល័យបាត់ដំបង កំពុងធ្វើបទសម្ភាសន៍ជាមួយនឹងកាសែតអ្នកនាំសារ។*

*ការសិក្សាគឺគ្មានប្រកាន់អំពីពណ៌សម្បុរ ឋានៈ តួនាទី ជីវភាពនោះទេ ប៉ុន្តែអ្វីដែលសំខាន់គឺ ឆន្ទៈ ដូច្នេះដើម្បីឲ្យដឹងច្បាស់ថា តើត្រូវបណ្តុះឆន្ទៈ និងការតាំងចិត្តយ៉ាងណាដើម្បីការអប់រំ* **អ្នកនាំសារ** *សូមអនុញ្ញាតណែនាំមិត្តអ្នកអានឲ្យជួបជាមួយនឹង* **លោក សម រ៉ានី** *នាយកវិទ្យាស្ថានភាសាបរទេសនៅសាកលវិទ្យាល័យបាត់ដំបង ដែលជាអតីតយុវជនដ៏ក្រីក្រ តែបានតស៊ូដើម្បីការសិក្សារហូតបានបណ្ឌិត។*

**អ្នកនាំសារ ៖** តើលោកបណ្ឌិតអាចជំរាបអំពីជីវប្រវត្តិ របស់លោកដោយត្រួសៗបន្តិចបានទេ?

**លោក សម រ៉ានី ៖** តាមពិតខ្ញុំគឺជាក្មេងដែលកើតនៅជំរំជាយដែន ហើយក៏ធ្វើមាតុភូមិនិវត្តន៍វិញមក នៅជុំគិរី ស្រុកឈូក ខេត្តកំពត នាឆ្នាំ១៩៩១ ហើយបានបន្តការសិក្សា នៅទីនោះរហូតដល់ចប់វិទ្យាល័យ ។ ពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ២០០៤ខ្ញុំបានមកបន្តការសិក្សានៅភ្នំពេញ រហូតចប់បរិញ្ញាប័ត្រច្បាប់ និងបន្តអនុបណ្ឌិតនៅក្នុងឆ្នាំ២០០៦ ។ នៅក្នុងឆ្នាំ ២០០៧ ខ្ញុំបានប្រឡងជាប់ក្របខ័ណ្ឌរដ្ឋ នៅសាកលវិទ្យាល័យបាត់ដំបង ហើយក៏បានរៀនធ្វើការ នៅនាយកដ្ឋានឧត្តមសិក្សាមួយឆ្នាំ ។ នៅឆ្នាំ ២០០៨ ខ្ញុំបានមកដល់សាកលវិទ្យាល័យបាត់ដំបង។ ដោយសារតែខ្ញុំជាស្ថាបនិកមួយរូបនៃសាកលវិទ្យាល័យនេះ ហើយក៏ជាអតីតបេក្ខជនជំនាន់ទីមួយ ដែលជាប់ការជ្រើសរើសការប្រឡងគ្រូឧត្តមសិក្សា ខ្ញុំក៏ទទួលបានការតែងតាំងជា នាយកវិទ្យាស្ថានភាសាបរទេស ប្រចាំនៅសាកលវិទ្យាល័យបាត់ដំបងនា ខែមីនា ឆ្នាំ ២០១០។ ដល់ឆ្នាំ ២០១១ ខ្ញុំក៏សំរេចចិត្ត ទៅបន្តការសិក្សាយកបណ្ឌិត ផ្នែករដ្ឋបាលឧត្តមសិក្សាដោយទទួលបានអាហារូបករណ៍ ពីរដ្ឋាភិបាលម៉ាឡេស៊ី និងសាកលវិទ្យាល័យ។

**អ្នកនាំសារ ៖** តើលោកមានប្រវត្តិគ្រួសារយ៉ាងណាដែរ ទើបអាចរៀនចប់ថ្នាក់បណ្ឌិត ទាំងក្មេងវ័យបែបនេះបានដូច្នេះ ?

**លោក សម រ៉ានី ៖** ខ្ញុំគឺជាពលរដ្ឋកម្ពុជាមួយរូបដែលចេញមកពីគ្រួសារក្រីក្រមួយ ដោយពេលនេះ មានឪពុកពិការ និងម្តាយគឺជាកសិករ។ តាមខ្ញុំចាំ មុនឆ្នាំ១៩៩៧ ក្រុមគ្រួសារខ្ញុំមានជីវភាពមធ្យមមួយ ដែលអាចមានធនធានគ្រប់គ្រាន់ ដើម្បីរៀន ប៉ុន្តែនៅឆ្នាំនោះពេលឪពុកខ្ញុំធ្លាក់ខ្លួនពិការ ដោយសារតែចូលទៅកាប់ឈើនៅព្រំដែន គ្រួសារបានធ្លាក់ចុះដុនដាបមែនទែន ហើយខ្ញុំត្រូវបានសាច់ញាតិ មិត្តភ័ក្រ និងអ្នកភូមិ បង្ខំឲ្យឈប់រៀនត្រឹមថ្នាក់ទី១១ ដើម្បីជួយសំរាលបន្ទុកគ្រួសារ ប៉ុន្តែនៅពេលនោះខ្ញុំបានសំរេចចិត្តមិនឈប់ដោយគិតថា បើឈប់ខ្ញុំនឹងជួបបញ្ហាធ្ងន់ធ្ងរជាងនេះ។

**អ្នកនាំសារ ៖** នៅពេលនេះយុវជនដែលក្រីក្ររៀនចប់វិទ្យាល័យ ហើយត្រូវចូលមហាវិទ្យាល័យ គឺមានច្រើន ប៉ុន្តែពួកគេមួយចំនួនធំ គឺជួបប្រទះបញ្ហាខ្វះខាតពិបាកដូចលោកបណ្ឌិតដែរ ដូច្នេះតើលោកចង់ឲ្យពួកគេបោះបង់ការសិក្សា ឬក៏បន្តដូចជាលោកបណ្ឌិត ?

**លោក សម រ៉ានី ៖** អត់ទេ ពួកគាត់គួរតែបន្តការសិក្សា។ ខ្ញុំគិតថា មានតែការអប់រំមួយទេ ដែលជាស្ពានចម្លងយើងទៅរកអនាគតភ្លឺស្វាង។ គ្មានការអប់រំ គឺគ្មានអ្វីៗទាំងអស់ដូចដែលយើងមើលទៅ ប្រទេសអភិវឌ្ឍ ធនធានមនុស្សគេសំបូរបែប។ ហើយតាមបទពិសោធន៍ អ្នកដែលជាប់បរិញ្ញាប័ត្រ គឺមិនដែលចោលម្សៀតនោះទេ។

**អ្នកនាំសារ ៖** តើលោកបណ្ឌិតអាចចែករំលែកបទពិសោធន៍ នៃការតស៊ូកាលពេលដែលលោករងសំពាធខ្លាំងកាលពីឆ្នាំ ១៩៩៧ តែលោកអាចជំនះបាននោះ ?

**លោក សម រ៉ានី ៖** តាមពាក្យស្លោកបរទេសមួយគឺថា "គ្មានការលំបាកគឺគ្មានការផ្លាស់ប្តូរទេ" ដូច្នេះប្រសិនបើយើងក្រីក្រ ហើយចេះតែផ្តេកផ្តួលថា យើងជាអ្នកក្រ ហើយមិនមានការអភិវឌ្ឍខ្លួនយើង ទៅរកអ្វីដែលថ្មីនោះទេ គឺយើងនឹងនៅដដែលដោយគ្មានការផ្លាស់ប្តូរ។ នៅពេលនោះខ្ញុំគិតតែម្យ៉ាងទេ គឺរៀនដើម្បីជាស្ពានចាកចេញពីភាពក្រីក្រនេះ។ ហើយខ្ញុំក៏បានបន្តខិតខំរហូត ដល់ទទួលបានលទ្ធផលមួយ ដែលគេទទួលស្គាល់ និងគោរព។ ខ្ញុំចាំបានថា នៅភូមិស្រុកនៅពេលនោះ គឺមានគំនិតមួយថា បើសិនជារៀនហើយអត់មានបក្សពួក អត់មានលុយ គឺអត់បានការអីទេ ប៉ុន្តែទោះបីជាគ្មានការគាំទ្រពីអ្នកនៅជុំវិញខ្លួន គឺខ្ញុំនៅតែអាចជំនះបាន។

**អ្នកនាំសារ ៖** តើលោកបណ្ឌិតអាចធ្វើយ៉ាងម៉េច ដើម្បីជំនះការលំបាកទាំងអស់នោះបាន ដោយសារនៅពេលនេះមានយុវជនមិនតិចទេដែលឆ្លងមិនផុតពីគន្លង នៃសំពាធបែបនេះ ?

**លោក សម រ៉ានី ៖** នៅពេលនោះ អ្វីដែលសំខាន់ គឺបណ្តុះឆន្ទៈរបស់យើងឲ្យរឹងមាំ ពោលគឺអ្នកដទៃគ្រាន់តែជាការផ្តល់គំនិត និង យោបល់ប៉ុណ្ណោះ។ ឆន្ទៈគឺសំខាន់ណាស់។

**អ្នកនាំសារ ៖** តើលោកអាចចែករំលែកបន្ថែមទៀតបានទេ ថាតើលោកបណ្តុះឆន្ទៈនេះតាមវិធីណា?

**លោក សម រ៉ានី ៖** ឆនៈនេះប្រហែលជាខ្ញុំអាចនិយាយបាន តាមរយៈការអានច្រើន ហើយខ្ញុំគឺយកគំរូពីថ្នាក់ ដឹកនាំណាដែលក្រីក្រដែរ ហើយយើងត្រូវតែគិតថា អ្វីដែលគេអាចធ្វើបានយើងក៏គួរតែអាចធ្វើបានដែរ ដូច្នេះសំខាន់គឺទឹកចិត្ត និងគោលដៅ។ នៅពេលនោះខ្ញុំគិតថា មានតែការអប់រំនេះទេ ដែលអាចនាំខ្ញុំចេញពីជ្រោះនៃភាពក្រីក្រនេះ ។

**អ្នកនាំសារ ៖** តើលោកបណ្ឌិតអាចចែករំលែកថែមទៀតបានទេ ជុំវិញការបណ្តុះឆន្ទៈនេះ ដោយសារតែពេលនេះ យុវជននៅកម្ពុជាជាច្រើន ជាពិសេសនៅជនបទ ដែលកំពុងតែប្រឈមមុខនឹងកង្វះឯកសារ និងមធ្យោបាយទទួលព័ត៌មានផ្សេងៗ?

**លោក សម រ៉ានី ៖** ឆន្ទៈដែលខ្ញុំមាននេះ គឺអាចប្រហែលជាខ្ញុំទទួលបានកាលនៅក្មេង ដោយសារតែកាលនៅជុំរុំ គឺនៅកំរិតមត្តេយ្យខ្ញុំបានទទួលការអប់រំច្រើនពីគ្រូបរទេស ហើយនៅទីនោះគឺគេបង្រៀនឲ្យខ្ញុំគិតអំពីអនាគតតាំងពីមតេយ្យថ្នាក់ទី១ ទី២ ទី៣ មកម្ល៉េះ ហើយខ្ញុំមានគំនិតចង់ធ្វើមេធាវីឬចៅក្រមតាំងពីពេលនោះមក។

**អ្នកនាំសារ ៖** រហូតមកដល់ពេលនេះ លោកបណ្ឌិតបានសំរេចជោគជ័យខ្លួនឯង នៅក្នុងការចាកចេញពីភាពអវិជ្ជា ដូច្នេះតើលោកអាចចែករំលែកយោបល់បន្តិច ចំពោះយុវជននានា ដែលកំពុងតែឆ្លងកាត់ស្ថានភាពដូច ឬ ប្រហាក់ប្រហែលនឹងលោកបណ្ឌិត ដោយផ្អែកលើធនធានដែលសហគមន៍ពួកគេមាន ?

**លោក សម រ៉ានី ៖** សម្រាប់ជាទុនមួយដែលអាចជួយដល់ពួកគាត់ឈានឆ្ពោះទៅរក ភាពជោគជ័យបាននោះ គឺ ព័ត៌មានជាប្រភពសំខាន់បំផុត។ គាត់ត្រូវតែព្យាយាមស្វែងរកព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយ ឲ្យទូលំទូលាយ ហើយត្រូវតែរៀនសូត្រ ពីរៀមច្បងដែលជោគជ័យ ហើយសិក្សាថា តើហេតុអ្វីបានជាគេបានជោគជ័យ ហើយគេទទួលជោគជ័យ តាមរបៀបណា ហើយតើយើងអាចរៀនសូត្រអ្វីខ្លះពីអ្នកដែលបានជោគជ័យហ្នឹង ហើយត្រូវរិះគិតថា ដើម្បីជោគជ័យ គឺត្រូវធ្វើអ្វីខ្លះ។ យើងចុងក្រោយគឺត្រូវតែមានគោលដៅច្បាស់លាស់ ពោលគឺគិតចង់ធ្វើត្រឹមតែកម្មករ កសិករ មន្ត្រី ឬ អ្នកជំនួញ ៕

**ដោយអរិយបុត្រ**

# ឆ្មាំយាមសន្តិសុខឯកជនរអ៊ូរឿងធ្វើការលើសម៉ោង និងប្រាក់ខែតិច



*រូបថតៈ សុន ម៉ៅ*

អង្គុយក្រោមផ័ត្រ មុខដីឡូតិ៍មួយកន្លែងដែលមានរបងបិទជិត ហើយមើលមិនយល់ថា ខាងក្នុងមានអ្វី នៅម្តុំ ភូមិសាស្ត្រ នៃតំបន់ទួលគោក គឺជាភ្នាក់ងារសន្តិសុខមួយរូប ដែលកំពុងតែអង្គុយរអ៊ូ រឿងធ្វើការចេះតែលើសម៉ោង និង ប្រាក់ខែតិច ហើយនិង ការព្រួយបារម្ភអំពីបញ្ហាសុខភាព ដោយសារតែការគេងមិនគ្រប់ ។

លោក លី ចាន់តុលា ជាមន្ត្រីក្រុមហ៊ុនសន្តិសុខមួយរូប បានអះអាងថា របរជាសន្តិសុខនេះ គឺមិនហត់ទេ ឬអស់កម្លាំងអ្វីឡើយ ។

លោកបានបន្តថានៅក្នុងមួយថ្ងៃៗ គឺលោកត្រូវធ្វើការ តែនៅក្រោមផ័ត្រតែប៉ុណ្ណោះ។ លោកបានបន្តទៀតថា ការងារនេះ គឺជាការងារដែលមិនចំណាយកម្លាំង ដូចការងារសំណង់ទេ ប៉ុន្តែវាគ្រាន់តែជាការងារ ដែលធ្វើទាំងភ្លៀង ទាំងក្តៅ ទាំងរងារ ហើយគ្មានថ្ងៃសំរាកទេ ជាពិសេសសម្រាប់អ្នកដែលត្រូវធ្វើការនៅវេនយប់ ដូចជារូបលោក ។

លោក តុលា បានឲ្យដឹងថា លោកបានបំរើការងារជាសន្តិសុខនេះ ជាងមួយឆ្នាំហើយ ដោយទទួលបានប្រាក់ខែ ១២០ ដុល្លារ មានបាយ និងមានកន្លែងស្នាក់នៅ ប៉ុន្តែជារបរមួយដែលយ៉ាប់ជាមួយនឹងការអត់ងងុយ។

លោក បានរអ៊ូបន្ថែមទៀតថា បើនិយាយអំពីការងារវិញ ជួនកាលគឺលើសពី១២ម៉ោងក៏មានដែរ នៅក្នុងមួយថ្ងៃៗ ប៉ុន្តែបើនិយាយអំពីប្រាក់កំរៃនៃការងារលើសម៉ោង ដែលលោកនិងក្រុមការងារ បានបំពេញនេះ គឺអត់មានតែម្តង ដែលនេះគឺជាបញ្ហា ។

លោកបានអះអាង "ខ្ញុំទ្រាំតែបើកប្រាក់ខែនេះរួច គឺសុំឈប់តែម្តងដោយសារតែខ្ញុំ ពិតជាមិនអាចទ្រាំទ្របានទេ ដោយសារវាអត់ងងុយ ។

លោកបានបញ្ជាក់ថា "ឥឡូវនេះមើលតែភ្នែកខ្ញុំឡើងស្លក់ ហើយដើរចេះតែងីងើៗ"។

លោកបានបន្តទៀតថា កាលពីពេលដំបូងឡើយ គឺធ្វើការត្រឹមតែ ៨ ម៉ោងទេ ហើយពេលថ្ងៃ គឺស្រួល ហើយប៉ះចំកន្លែងអង្គការ គឺស្រួលមែនទែន ទោះជាពេលនោះប្រាក់ខែតែ៩០ដុល្លារក៏ដោយប៉ុន្តែជួនអង្គការគេឧបត្ថម្ភខ្លះ ឲ្យថ្លៃធ្វើដំណើរ ថ្លៃបាយពេលគេធ្វើការលើសម៉ោង តែក្រោយមក អង្គការប្តូរទីតាំង ក៏ឈប់ជួលសន្តិសុខ ហើយលោកក៏ផ្លាស់ប្តូរមកវេនយប់វិញ។

លោកបានបន្តទៀតថា ពេលធ្វើការយប់នេះ គឺលំបាកសព្វយ៉ាង តាំងពីអត់ងងុយ ពេលខ្លះភ្លៀង ពេលខ្លះខ្លាចផង ដោយសារតែបិទភ្លើងដេកស្ងាត់ជ្រាប យើងអង្គុយយាមតែឯងក្រោមពន្លឺភ្លើង មើលទៅកំសត់ខ្លួនណាស់។

លោកបានបន្តទៀតថា ធ្វើជាសន្តិសុខវេនយប់នេះ គឺលោកមកធ្វើចាប់ពីម៉ោង ៦ ល្ងាច ដល់ ម៉ោង៦ ព្រឹក ដោយក្រុមហ៊ុន គេមានឡានដឹក តែជួនកាលយាមដល់ម៉ោង ៨ ព្រឹក ក៏មានដែរ ដោយក្រុមហ៊ុនយកលេស ថាស្ទះចរាចរណ៍ហើយអត់មានលុយលើកទឹកចិត្តអ្វីនោះទេ ជួនកាលទៅក្រុមហ៊ុនវិញ គឺអត់បានដេកថែមទៀត ដោយសារតែទៅជំនួសគេដែលគេសុំច្បាប់សុំអីថែមទៀត ។

លោកបានបន្តទៀតថា "ខ្ញុំទ្រាំមិនបានទៀតទេ ខែក្រោយនេះបើក្រុមហ៊ុនឲ្យនៅយប់ទៀត គឺឈប់ហើយ ទោះបីជាក្រុមហ៊ុនសន្យាថា នៅខែក្រោយនឹងតម្លើងដល់ ១៥០ ដុល្លារ នៅក្នុងមួយខែក៏ដោយ"។

លោក ស៊ីត ប៉ូវ៉ា ជាអ្នកយាមឡាននៅហាងកាហ្វេមួយ នៅម្តុំស្តុបមេភ្លើង បានឲ្យដឹងថា លោកមិនមានប្រាក់ខែទេ គឺលោកសុំហាងធ្វើ តែលោកអាចរកក្រៅបាន ដោយសារភ្ញៀវ គេចេះតែហុចឲ្យ ដោយម៉ូតូគេឲ្យ ៥០០រៀល ទៅ១.០០០ រៀល ហើយបើឡានវិញ គឺមានពី ១០០០រៀលឡើង អ្នកខ្លះទូលាយ គេឲ្យដល់មួយដុល្លារ ដល់ ៥០០០ រៀលក៏មាន ។

លោកបានបញ្ជាក់ថា "អត់មានប្រាក់ខែទេតែមួយថ្ងៃគឺខ្ញុំអាចរកបានប្រហែលជា ៥ទៅ ៦ រៀល ( ដុល្លារ ) ហើយបាយ គឺបានហាងគាត់ជួយផ្តល់ឲ្យ"។

លោក ប៉ូវ៉ា បានបន្តទៀតថា ការងារ លោកមិនជាលំបាកទេ ដោយគ្រាន់តែ ជួយមើលយានយន្ត ឲ្យគេហើយបើឡានវិញ គឺជួយឲ្យគេថយ និង ចតតែប៉ុណ្ណោះ ហើយម៉ោងពេលក៏មិនកំណត់ គឺអាស្រ័យលើភ្ញៀវ ប៉ុន្តែលោកដឹងតែពីម៉ោង ៦ ព្រឹកគឺទៅដល់ហាង ។

រហូតមកដល់ពេលនេះ ក្រុមហ៊ុនសន្តិសុខ គឺមានច្រើន ហើយអ្នកដែលប្រកបរបរជាសន្តិសុខនេះ រឹតតែមានច្រើន ហើយរបៀបរបប និងលក្ខខណ្ឌជ្រើសរើស ក៏ដូចជារឿងប្រាក់ខែនោះ គឺ ថាទៅតាមក្រុមហ៊ុនដែលសន្តិសុខម្នាក់ៗធ្វើការ ។

កាលពីចុងខែ មីនា ឆ្នាំ២០១៥ កន្លងទៅនេះ ក្រុមហ៊ុនសន្តិសុខមួយថ្មីបានប្រកាសបើក ដោយក្រុមហ៊ុននេះគឺត្រូវបានគេដឹងថា គឺរួមហ៊ុនគ្នារវាងសិង្ហបូរី និង អ្នកវិនិយោគទុននៅក្នុងស្រុកហើយប្រកាសផ្តល់សេវាមួយ ដែលមានលក្ខណៈជាក្រុមហ៊ុនស្តង់ដា។

ក្រុមហ៊ុននេះ ត្រូវបានគេដឹងថា ក្រុមហ៊ុនសន្តិសុខលីដែន&ហ្វេបៀន ស៊ីយ្យូរីធី ហូលឌីង ខូអិលធីឌី ដែលមានលោក នឹម ច័ន្ទតារា ជានាយកប្រតិបត្តិ។

លោក នឹម ច័ន្ទតារា បានអះអាងថា ជាមួយនឹងការអភិវឌ្ឍសេដ្ឋកិច្ច-ស្ថិតក្នុងកម្រិត៧ភាគរយ នៃផលទុនជាតិសរុប និងនយោបាយទាក់ទាញការវិនិយោគទុនពីក្រៅប្រទេស រួមនឹងការជំរុញ វិនិយោគទុនក្នុងប្រទេសបច្ចុប្បន្នទីផ្សារកម្ពុជា កំពុងត្រូវបានអ្នកវិនិយោគទុនបរទេស ចូលមកបណ្តាក់ទុនគ្រប់វិស័យ ដូច្នេះហើយបានជាក្រុមហ៊ុននេះ ត្រូវបានបង្កើតឡើងដើម្បីចូលរួមចំណែកនៅក្នុងការថែរក្សាសន្តិសុខរបៀបរៀបរយ។

លោកបានអះអាងថា ក្រុមហ៊ុននេះ នឹងរៀបរៀងឲ្យទៅជាក្រុមហ៊ុនសន្តិសុខដែលមានស្តង់ដាមួយ ដើម្បីជាទំនុកចិត្តដល់អ្នកវិយោគគិន។

លោកបានបន្តទៀតថា នៅកម្ពុជានាពេលបច្ចុប្បន្ននេះ គឺមានសន្តិភាពនិងស្ថេរភាព ប៉ុន្តែតំរូវការ នៃសេវាកម្មសន្តិសុខគឺនៅតែត្រូវការចាំបាច់ ៕

**ដោយអរិយបុត្រ**

# អង្គភាពប្រឆាំងអំពើពុករលួយប្រឆាំងជាថ្មីរឿងមន្ត្រីខ្មោច

អង្គភាពប្រឆាំង អំពើពុករលួយ កាលពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៥ បានធ្វើការព្រមានជាថ្មី ដល់ប្រធានស្ថាប័ន និង អង្គភាពគ្រប់លំដាប់ថ្នាក់នានារបស់រដ្ឋរឿងមន្ត្រីខ្មោច។

យោងទៅតាមសេចក្ដីជូនដំណឹងរបស់ស្ថាប័ននេះ បានឲ្យដឹងថាប្រធានស្ថាប័នអង្គភាពគ្រប់លំដាប់ថ្នាក់នានារបស់រដ្ឋ នឹងប្រឈមមុខនឹងទោស ប្រសិនបើមានការរក្សាទុកនូវបញ្ជីឈ្មោះមន្ត្រីខ្មោច។

សេចក្ដីជូនដំណឹងនោះ បានអះអាងថា មកដល់ថ្ងៃនេះ អង្គភាពប្រឆាំងអំពើពុករលួយ នៅតែទទួលបានពាក្យប្ដឹងជាបន្តបន្ទាប់ ដែលបានរៀបរាប់ថា មានមន្ត្រីមានឈ្មោះ តែមិនមកធ្វើការ ហើយករណីខ្លះទៀតប្រាក់ខែអ្នកទាំងនោះ ត្រូវបានគណនេយ្យករ ឬប្រធានអង្គភាពនៅទីនោះ យកមកចាយវាយជាបុគ្គល ឬជាសមូហភាព។ អង្គភាពប្រឆាំងអំពើពុករលួយ បានបញ្ជាក់ថា ការរក្សាទុកនូវបញ្ជីឈ្មោះអ្នកមិនមកធ្វើការ ក្នុងគោលបំណងយក ឬមិនយកនូវប្រាក់បៀវត្សអ្នកទាំងនោះក្ដី គឺជាបទល្មើសមួយ ដែលនឹងត្រូវផ្ដន្ទាទោសតាមច្បាប់ជាធរមាន៕

# វៀតណាមជំរុញការពង្រឹងម៉ាក/យីហោអង្ករបស់ខ្លួន

នៅក្នុងកិច្ចប្រឹងប្រែង ដើម្បីជំរុញកិត្តិនាមអង្ករនាំចេញរបស់ខ្លួន ក្រសួងកសិកម្ម និងអភិវឌ្ឍជនបទ នៃប្រទេសវៀតណាមបានប្រកាសដាក់ចេញនូវ ផែនការមួយទៅរដ្ឋាភិបាល ដើម្បីពង្រឹង ម៉ាក/យីហោ អង្កររបស់វៀតណាមនៅឆ្នាំ ២០២០។

តាមប្រព័ន្ធផ្សព្វផ្សាយវៀតណាម បានឲ្យដឹងថា ក្រសួងកសិកម្ម និងអភិវឌ្ឍជនបទវៀតណាម បានអះអាងថា វៀតណាមគឺជាប្រទេសនាំអង្ករចេញមួយ នៅក្នុងចំណោមប្រទេសនាំចេញអង្ករធំបី នៅលើពិភពលោកប៉ុន្តែម៉ាក/យីហោអង្ករវៀតណាម នៅតែជាបញ្ហាខណៈដែលកង្វះសង្គតភាព ក្នុងកម្រិតគុណភាព និង ស្តង់ដាអនាម័យមិនគ្រប់គ្រាន់ នៅតែជាបញ្ហាប្រឈម។

កាលពីឆ្នាំ២០១៤ ខេត្តនៅតាមដីសណ្ដរបាននាំចេញអង្ករគុណភាពខ្ពស់៣,២ លានតោន ត្រូវជា ៥២% នៃការនាំចេញសរុប ពោលគឺមានការកើនឡើងប្រមាណជា ៤៤%បើធៀបនឹងឆ្នាំ២០១៣ ដោយទីផ្សារនាំចេញវៀតណាម គឺ សហភាពអឺរ៉ុប អាមេរិកខាងជើង អាស៊ី និងអាហ្វ្រិក ៕

# ប្រមុខរដ្ឋាភិបាលកម្ពុជារិះគន់អាមេរិករឿងអាហារូបករណ៍ជួយយុវសិស្សនារីក្រីក្រ

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា កាលពីព្រឹកថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១៥ បានរិះគន់ទៅលើអាមេរិក ជុំវិញរឿងអាហារូបករណ៍ជួយយុវសិស្សនារីក្រីក្រ នៅសៀមរាប និងបានស្នើសុំឲ្យក្រសួងអប់រំពិភាក្សា ជាមួយនឹងអាមេរិក អង្គការ USAID និង អង្គការដែលពាក់ព័ន្ធជុំវិញបញ្ហានេះ ។

សម្ដេចតេជោ ហ៊ុន សែន នាពិធីចែកសញ្ញាប័ត្រនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ បានស្នើឲ្យគិតគូរឡើងវិញនូវកម្មវិធីលើកស្ទួយការអប់រំ ក្មេងស្រី និង ស្ត្រីក្នុងប្រទេសកំពុងអភិវឌ្ឍឲ្យបានរៀនសូត្រជ្រៅជ្រះគឺ "Let Girls Learn" ឲ្យគិតគូរឡើងវិញ អំពីយន្តការផ្ដល់អាហារូបករណ៍ និង ការជ្រើសរើស។

តាមប្រសាសន៍របស់ សម្ដេចតេជោ ហ៊ុន សែន កម្មវិធីលើកស្ទួយការអប់រំក្មេងស្រី និងស្ត្រីក្នុងប្រទេសកំពុងអភិវឌ្ឍឲ្យបាន រៀនសូត្រជ្រៅជ្រះគឺ "Let Girls Learn" ដែលកាលពីសប្ដាហ៍មុន បានទាក់ទាញការបំពេញទស្សនៈកិច្ច ពីលោកជំទាវទីមួយអាមេរិក មីសែល អូបាម៉ា មកកាន់ខេត្តសៀមរាបថា បានផ្ដល់អាហារូបករណ៍ដល់ពួកគេត្រឹមតែ ៦ ឆ្នាំហើយបានស្នើសុំឲ្យ សម្ដេចបន្តជួយគាំទ្រ ៤ ឆ្នាំទៀត។

ជុំវិញដំណើរការនេះសម្ដេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា សម្រាប់ឆ្នាំដំបូងនេះ គឺ សម្ដេចទទួល ប៉ុន្តែនៅពេលក្រោយ សុំឲ្យក្រសួងអប់រំពិភាក្សាឡើងវិញ ជាមួយនឹងអង្គការ USAID និងអង្គការដែលពាក់ព័ន្ធជុំវិញ ។

សម្ដេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា យន្តការនេះល្អ ពីព្រោះស្ថានភាពក្មេងស្រី ដែលបោះបង់កាសិក្សាមានច្រើន ជាងក្មេងប្រុស តែត្រូវទាមទារនូវយន្តការប្រកដប្រជាមួយ បើមិនដូច្នេះទេ វាអាចមានបញ្ហាជាពិសេស គឺការទទួលខុសត្រូវ ។

សម្ដេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា នេះសំណាងរើស១០រូប ចុះបើរើសបាន ១០០ នាក់ ឬច្រើនជាងនេះ អ្នកណាទទួលខុសត្រូវ ។

សម្ដេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថាបើជួយ គួរជួយឲ្យចប់ចុងចប់ដើមយ៉ាងហោចគឺពី៨ឆ្នាំទៅ១០ឆ្នាំ ៕

# កំណើនសេដ្ឋកិច្ចរបស់កម្ពុជា គឺនៅតែរឹងមាំ

របាយការណ៍ថ្មីមួយ របស់ធនាគារអភិវឌ្ឍអាស៊ី ដែលចេញផ្សាយកាលពីថ្ងៃទី២៤ ខែមីនា បានឲ្យដឹងថា សេដ្ឋកិច្ចរបស់កម្ពុជា នឹងបន្តរីកចម្រើនរឹងមាំដដែល នៅក្នុងឆ្នាំនេះ និង នៅឆ្នាំក្រោយ។

ស្ថាប័នហិរញ្ញវត្ថុមួយនេះបានឲ្យដឹងថា ផលិតផលក្នុងស្រុក សរុបរបស់កម្ពុជា ត្រូវបានព្យាករណ៍ថានឹងមានការកើនឡើងពី៧,០% ក្នុងឆ្នាំ២០១៤ រហូតដល់ ៧,៣% ក្នុងឆ្នាំ២០១៥ ហើយនឹងបន្តកើនឡើងដល់ ៧,៥% នៅឆ្នាំក្រោយ។

ប្រភពដដែល បានបន្តទៀតថា ការកើនឡើងនូវតម្រូវការ ក្នុងស្រុក និងភាពរឹងមាំ នៃកិច្ចខិតខំប្រមូលពន្ធ បានធ្វើឱ្យឱនភាពហិរញ្ញវត្ថុ ដោយមិនរាប់បញ្ចូល ទាំងជំនួយឥតសំណង រួមតូចមក ត្រឹមប្រមាណ ៤,១% នៃ GDPកាលពី២០១៤។

លោក អេរិច ស៊ីដវិច នាយកធនាគារអភិវឌ្ឍអាស៊ី ប្រចាំប្រទេសកម្ពុជា មានប្រសាសន៍ថា ស្ថានភាពរឹងមាំនេះ គឺដោយសារភាពកាន់តែរឹងមាំនៃសេដ្ឋកិច្ចពិភពលោកនិងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ប្រកបដោយការប្រុងប្រយ័ត្នរបស់កម្ពុជា។

ទោះបីជាសេដ្ឋកិច្ចកម្ពុជា នៅក្នុងឆ្នាំនេះ នឹងឆ្នាំក្រោយនៅរឹងមាំ ប៉ុន្តែនាយកស្ថាប័ននេះ ជំរុញឲ្យកម្ពុជាបន្តកំណែទម្រង់ថែមទៀត ដើម្បីនិរន្តរភាព នៃកំណើនសេដ្ឋកិច្ច ។

លោកបានបន្តទៀតថា ប្រទេសកម្ពុជាត្រូវបន្តពង្រីកមូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួន និង ធ្វើពិធកម្មប្រភពកំណើន ដើម្បីគាំទ្រដល់កំណើនសម្រាប់ទាំងអស់គ្នា និងកំណើនដែលមាននិរន្តរភាព៕

# ជីវភាពគឺជាបញ្ហាប្រឈមថ្មីសម្រាប់ពលរដ្ឋដែលផ្ទុកមេរោ

ក្រៅពីទឹកចិត្ត និង សុខភាពមានការទ្រុឌទ្រោមបញ្ហាថ្មី ដែលប្រជាពលរដ្ឋ ដែលផ្ទុកមេរោគអេដស៍ប្រមាណជា ២៨០ នាក់ នៅក្នុងឃុំរកា កំពុងតែប្រឈមគឺបញ្ហាជីវភាព ។

តាំងតែពីបញ្ហា ផ្ទុះការឆ្លងរីករាលដាលជំងឺអេដស៍ បានកើតមានឡើង តាំងតែពីចុងឆ្នាំ ២០១៤ មកដល់ពេលនេះ ប្រជាពលរដ្ឋរងគ្រោះ គឺកំពុងតែ ទទួលបាននូវការយកចិត្តទុកដាក់ តាំងពីកំរិតមូលដ្ឋានរហូតដល់ថ្នាក់កំពូលហើយសេវាសុខភាពដែលផ្តល់ដល់ពួកគេក៏សមរម្យ នឹងទទួលយកបាន ប៉ុន្តែអ្វីដែលជាកង្វល់របស់ប្រជាពលរដ្ឋ នៅក្នុងសហគមន៍នេះនៅតែបារម្ភនោះ គឺបញ្ហានៃការធ្លាក់ចុះនៃជីវភាព ។

លោក កាន សម្បត្តិ ជំទប់ទីមួយឃុំរកា បានមានប្រសាសន៍ថា នេះគឺជារឿងដែលមិនគួរឲ្យជឿ ដែលកើតមានមកលើប្រជាពលរដ្ឋនៅក្នុងឃុំ។ លោកបានបញ្ជាក់ថានៅក្នុងចំណោមប្រជាពលរដ្ឋចំនួន ២.០៩៩ ដែលរស់នៅក្នុងភូមិចំនួន ៦ មានគ្រួសាររហូតដល់ទៅ ២០៧ គ្រួសារដែលរកឃើញមានអ្នកផ្ទុកមេរោគអេដស៍ ។

លោកបានបញ្ជាក់ថា "ពីរភូមិនៅក្នុងចំណោម ៦ភូមិ គឺរកឃើញថាមានអ្នកផ្ទុកសឹងតែទាំងអស់ ដោយគ្រួសារ ខ្លះគឺទាំងអស់ក៏មានទាំងកូនទាំងចៅ ទោះបីអាតូចៗអត់ទាន់ដឹងអីក៏ផ្ទុកដែរ"។

លោកបានឲ្យដឹងថា ក្រោយពេលរកឃើញជំងឺនេះគ្រប់ផ្ទះ ឮសូរតែសម្លេងទុក្ខសោក និង យំស្រែកហើយនៅពេលនេះគឺស្ថានភាពទុកសោកគឺកំពុងតែរសាយ ដោយសារតែពួកគេទទួលភាពកក់ក្តៅច្រើនពីថ្នាក់ដឹកនាំដែលតែងតែចុះមកជាប្រចាំ ដើម្បីបំផុសណែនាំបញ្ហាហ្នឹង កុំឲ្យគាត់បាក់ធ្លាក់ទឹកចិត្ត ហើយមានការចែកជូនថ្នាំពន្យាថ្នាំព្យាបាលជំងឺដោយមិនគិតថ្លៃ ជាហេតុឲ្យពួកគាត់រសាយបន្តិច ប៉ុន្តែបញ្ហាដែលកំពុងតែចោទមួយ ហើយជាបញ្ហាចំបង គឺបញ្ហាជីវភាព ដែលពួកគេកំពុងតែប្រឈមមុខនឹងបញ្ហា ។



*ស្ត្រី និងកូន អ្នកភូមិរកា ផ្ទុកមេរោគអេដស៍មកទទួលការប្រឹក្សាយោបល់អំ*

លោកបន្តថា ជីវភាពពួកគាត់យ៉ាប់ ដោយសារតែភាគច្រើននៃគ្រួសារតែផ្ទុកគឺភាគច្រើនជាជនបង្គោលនៅក្នុងគ្រួសារ ដែលជាឪពុក ឬជាម្តាយ ដែលត្រូវទៅរកចំណូលចូលគ្រួសារ ។

លោកបានបញ្ជាក់ថា "ការផ្ទុះមេរោគអេដស៍នេះ គឺកំពុងតែបង្ករការលំបាកមែនទែន ដល់ប្រជាពលរដ្ឋជាក់ស្តែងគ្រួសារខ្លះមានសមាជិក ៥ នាក់ គឺកើតដល់ទី ៤ នាក់ ខ្លះទៀតទាំងគ្រួសារ ខណៈដែលអាជីពពួកគេភាគច្រើន គឺធ្វើស្រែ នេសាទឆ្ងាយៗពីផ្ទះ ប៉ុន្តែឥឡូវនេះ គឺចេញពីផ្ទះទៅឆ្ងាយលែងកើត" ។

លោកស្រី សឿន សុភាត អនុប្រធានមណ្ឌលសុខភាពរកា បានមានប្រសាសន៍ថា មកទល់នឹងពេលនេះមណ្ឌលសុខភាព អាចមានលទ្ធភាពផ្តល់សេវាពិគ្រោះជំងឺ ចែកថ្នាំប្រឆាំងមេរោគអេដស៍ និងជំងឺឱកាសនិយម ដូចជាថ្នាំព្យាបាលជំងឺរបេង បានជានា ដោយមានក្រុមគ្រូពេទ្យជំនាញពីភ្នំពេញចុះមកជួយថែមទៀត រីឯថ្នាក់ដឹកនាំក្រសួងក៏យកចិត្តទុកដាក់ ចុះមកជាបន្តបន្ទាប់ ប៉ុន្តែនៅពេលនេះ អ្វីដែលជាកង្វល់របស់ពួកគាត់ គឺភាពក្រីក្រ ដោយតែពួកគាត់មិនអាចធ្វើដំណើរទៅធ្វើការនៅទីឆ្ងាយៗ ដូចដែលពួកគេធ្លាប់ទៅពីមុន ព្រោះពួកគាត់ត្រូវតំរូវឲ្យនៅតាមដានសុខភាព និងនៅចាំបើកថ្នាំពន្យាជីវិត ហើយម្យ៉ាងទៀតពេលដែលលេបថ្នាំនេះទៅ គឺពួកគាត់អាចធ្វើទុក្ខ នៅក្នុងខ្លួន ហេិតហៃ ក្អួតចង្អោរពិបាកនឹងធ្វើការ ។

លោកស្រី ប៉ា សុខាល័យ មន្ត្រីនៃអង្គការពុទ្ធសាសនា ដើម្បីអភិវឌ្ឍបាន មានប្រសាសន៍ថា នៅក្នុងចំណោមអ្នកផ្ទុក ដែលយើងកត់ត្រាប្រមាណជា ២៨០នាក់ ដែលមន្ត្រីសុខភាពរកឃើញនៅក្នុងឃុំរកានេះ គឺមាន ៦នាក់បានបាត់បង់ជីវិតហើយដោយភាគច្រើន គាត់ជាមនុស្សចាស់ ដែលមានសុខភាពទ្រុឌទ្រោមស្រាប់។

លោកស្រី បានកត់សំគាល់ថានៅក្នុងស្ថានភាពបច្ចុប្បន្ននេះ គឺនៅក្នុងចំណោមអ្នកផ្ទុក គឺកំពុងតែត្រូវបានយកចិត្តទុកដាក់ ហើយមណ្ឌលសុខភាពក៏មានសេវាកម្មគ្រប់គ្រាន់ ដើម្បីជួយសំរួល និង ព្យាបាលដល់ពួកគាត់ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ទឹកចិត្តពួកគាត់នៅទុនខ្សោយហើយត្រូវការពេលវេលាថែមទៀត ដើម្បីឲ្យពួកគាត់រសាយចិត្ត។

លោកស្រីបញ្ជាក់ថា "ពេលជួប

## ព្រះសហគមន៍កាតូលិកនៅជាប់ជាមួយនឹងបងប្អូនរងគ្រោះដោយសារជំងឺអេដស៍នៅរកា

ព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបងបានអះអាងថា នឹងបន្តបេសកម្មមនុស្សធម៌ និងនៅរួមរស់ជាមួយនឹងបងប្អូនរងគ្រោះ រហូតអស់មួយជីវិត ។

លោក ហ្សេរីកូ បារីរស អ្នកស្ម័គ្រចិត្ត ទទួលបន្ទុកកម្មវិធីចុះមូលដ្ឋាននៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង បានមានប្រសាសន៍ថាពួកយើងដឹងអំពីបញ្ហានេះតាំងពីដំបូងដោយសារតែយើងមានព្រះវិហារមួយនៅក្នុងឃុំរកា នៅក្នុងភូមិតាហែន។

លោកបានមានប្រសាសន៍ថា យើងមិនមែនមកពីក្រៅទេ ពួកយើងមិនមែនដឹងដោយសារកាសែត ឬ ព័ត៌មាន ហើយគ្រីស្តបរិស័ទយើង ក៏មានបញ្ហានេះផងដែរ ។

លោកបានបញ្ជាក់ថា "បញ្ហានេះ គឺជាបញ្ហាយើងនៅក្នុងព្រះសហគមន៍យើង" ។

លោកបានបន្តទៀតថា ព្រះសហគមន៍កាតូលិក និងអង្គការផ្សេងៗ គឺមានគោលដៅតែមួយទេ គឺជួយអ្នកជំងឺ ប៉ុន្តែយើងមិនមែនផ្តោតអារម្មណ៍តែទៅលើអ្នកដែលផ្ទុកមេរោគអេដស៍ទេ គឺពួកយើងផ្តោតអារម្មណ៍ទៅលើជំងឺរុំារ៉ៃ អ្នកទុគ៌ត ជនចាស់ជរាផងដែរ ។

លោកបានបន្តទៀតថា តាមគម្រោងព្រះសហគមន៍កាតូលិកនឹងរៀបចំក្រុមការងារ ដែលមានសមាជិកប្រហែលជា៦ នាក់ ដោយនៅក្នុងនោះ គឺមានអ្នកស្ម័គ្រចិត្តមកពីតាហែន រកា ពេទ្យឃាយជី និងអ្នកផ្ទុកផងដែរ ដើម្បីនៅជាមួយនឹងបងប្អូន ៕

# អេដស៍នៅក្នុងភូមិរកា



ការថែរក្សាសុខភាព ពីមន្ត្រីអង្គការក្រៅរដ្ឋាភិបាលមួយ ។ ដោយលី សុវណ្ណា

គាត់ក្រោយពេលទទួលលទ្ធផលឈាម គឺគួរឲ្យរន្ធត់ ម្នាក់ៗគ្មានអ្វីក្រៅពីទឹកភ្នែក អ្នកខ្លះយំសឹងតែបោកខ្លួន"។

លោកស្រីបានបន្តទៀតថា នៅពេលបច្ចុប្បន្ននេះស្ថានភាពសេដ្ឋកិច្ចគឺលំបាក ដោយសារតែអ្នកដែលផ្ទុកគឺភាគច្រើន ប៉ះទៅលើអ្នកដែលរកចំណូលចូលគ្រួសារ ពីព្រោះអ្នកដែលរកចំណូល ពេលដែលប្រើប្រាស់ថ្នាំនេះគឺគាត់មិនអាចទៅណាឆ្ងាយបានយូរទេ ព្រោះមួយខែ គាត់ត្រូវតែមកបើកថ្នាំម្តង ដូច្នេះ គឺគាត់អាចទៅតែជិតៗនេះ ដែលល្មមអាចឲ្យគាត់មកបើកថ្នាំទាន់ ។

លោកស្រីបានបញ្ជាក់ថា នៅទីនេះយ៉ាប់ដែរ ដោយសារតែពួកគាត់ត្រូវទៅនេសាទនៅរនាម យូៗបានមកផ្ទះម្តង ដូច្នេះចំណូលគឺគាត់គឺយ៉ាប់។ វាពិតជាលំបាក ដូចជាគ្រួសារខ្លះ គឺសមាជិក១៨ នាក់ គាត់ផ្ទុកទាំងអស់ទាំងកូនកូនប្រសារ ចៅ គឺទាំងអស់ ។

បងស្រីមួយរូប ដែលមានអាយុ ៣៥ឆ្នាំ ជាម្តាយកូន ៣នាក់នៅក្នុងបន្ទុក និង ជាអ្នកជំងឺផ្ទុកមេរោគអេដស៍មួយរូបនៅភូមិរកា ឃុំរកា ស្រុកសង្កែនោះបានឲ្យដឹងថា នៅក្នុងពេលនេះ មានតែបងស្រីមួយប៉ុណ្ណោះដែលផ្ទុក ប៉ុន្តែពេទ្យប្រាប់ថា ស្វាមីនិងកូនៗទាំងបីនាក់ទៀត គឺត្រូវបន្តតាមដានពីបីខែ ទៅ៦ខែបន្តទៀត ។

បងស្រី បានអះអាងក្រោយពេលដែលមកមណ្ឌលសុខភាពជួបពិគ្រោះយោបល់និងទទួលថ្នាំពន្យាពីគ្រូពេទ្យថា នៅពេលនេះ ទុក្ខសោកនៃការឆ្លងគឺដូចជារយាលហើយ ប៉ុន្តែក្តីបារម្ភ គឺសុវត្ថិភាពប្តីនិងកូន ។

បងស្រី បានបញ្ជាក់ថា "ឥឡូវនេះរកឃើញផ្ទុកតែខ្ញុំទេ ប៉ុន្តែបើប្តីកូនខ្ញុំផ្ទុកដូចគ្រួសារគេទៀត ខ្ញុំមិនដឹងជាគិតយ៉ាងណាទ" ។

បងស្រី បានឲ្យដឹងថា នៅក្នុងគ្រួសារនៅពេលនេះ កំពុងតែជួបបញ្ហាសេដ្ឋកិច្ចខ្លះៗ ដោយសារតែប្តីដែលធ្លាប់ចេញទៅធ្វើការ នៅប៉ោយប៉ែតយូរៗមកម្តងគឺមិនអាចចេញទៅបានដោយសារខ្ញុំឈឺ ។

លោក ពូ អាយុ ៥១ ឆ្នាំ ដែលត្រូវបានគេដឹងថា គឺជាអ្នកដែលនាំឲ្យមានការសង្ស័យ អំពីបន្ទុះនៃការឆ្លងមេរោគអេដស៍ដំបូងគេ បានអះអាងថា សព្វថ្ងៃនេះលោកពូកំពុងតែបារម្ភនឹងបន់ព្រះ សុំកុំឲ្យកូនប្រុស និងកូនស្រីរបស់លោកពូឆ្លងមេរោគនេះអី ។

លោកពូបានបញ្ជាក់ថា កូនស្រីម្នាក់ និង ប្រុសម្នាក់ គ្រូពេទ្យរកមិនទាន់ឃើញមានផ្ទុកមេរោគទេ តែពេទ្យថា រង់ចាំប្រហែលជា ៣ ទៅ៦ ខែទៀតទើបហ៊ានអះអាងពិតប្រាកដ ។

ជុំវិញបញ្ហាសេដ្ឋកិច្ចនេះ លោក ពូ បានអះអាងថា សម្រាប់គ្រួសារលោក ពូ ក៏កំពុងប្រឈមមុខនឹងបញ្ហានេះដែរ ពីព្រោះពេលនេះ កំពុងតែរហិតរហៃធ្វើអ្វីមិនកើត។ លោកពូ បានអះអាងថា ពីមុនដើរកស្មៅគោលីម្តងមួយបាវអី ឥឡូវនេះលីតែកន្លះបាវគឺទន់ជង្គង់តែម្តង។ លោកពូ បានបន្តទៀតថា សម្រាប់គ្រួសារលោកពូ គឺនៅមានក្តីសង្ឃឹមខ្លះ ប៉ុន្តែវារិតតែកំសត់សម្រាប់គ្រួសារដែលផ្ទុកទាំងអស់គ្នាតាំងពីតាដល់ចៅៗដែលជាក្មេងៗតូចៗមិនដឹងខ្យល់អីនៅឡើយនោះ ។

ជុំវិញបញ្ហាដែលចោទ នៅក្នុងសហគមន៍បែបនេះ លោក កាន សម្បត្តិ បានឲ្យដឹងថា នៅពេលនេះ ឃុំ កំពុងតែទាក់ទងរាជរដ្ឋាភិបាល អង្គការនានាដើម្បីជួយ។ លោកបានបន្តទៀតថា សព្វថ្ងៃនេះ អង្គការខាងពុទ្ធសាសនា និង ព្រះសហគមន៍កាតូលិក គឺកំពុងតែធ្វើកិច្ចការនេះខ្លះៗ ជាពិសេស គឺការបណ្តុះបណ្តាលពន្យល់ប្រជាជន អំពីការដាំដុះដំណាំនៅជិតៗផ្ទះ។

លោកស្រី ប៉ា សុខាល័យ បានឲ្យដឹងថា ជុំវិញការលំបាកនេះ គឺថាខាងអង្គការក្រៅពីជួយ នៅពេលបច្ចុប្បន្ននេះ អង្គការកំពុងតែសំរបសំរួលជួយពួកគាត់ឲ្យបង្កើត ជាសហគមន៍មួយ ហើយពួកយើង កំពុងតែសង្ឃឹមថានឹងរកដៃគូជាមួយ នឹងអង្គការផ្សេងៗ ដើម្បីជួយលើចំណុចនេះ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ គឺអង្គការមិនទាន់ដឹងថាវាយ៉ាងណានោះទេដោយសារតែពេលនេះ ក្រុមការងារលោកស្រីដែលកំពុងធ្វើនៅរកា គឺបានការឧបត្ថម្ភ ពីអង្គការដៃគូ ត្រឹមដំណាក់កាលដំបូង ៥ ខែប៉ុណ្ណោះ ។

លោក ហ្វេឌីរីកូ បារីរាស អ្នកស្ម័គ្រចិត្តទទួលបន្ទុកកម្មវិធី ចុះតាមសហគមន៍ របស់ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងបានឲ្យដឹងថា ព្រះសហគមន៍គឺកំពុងតែនៅជាប់ជាមួយនឹងបងប្អូនរងគ្រោះ នៅពេលបច្ចុប្បន្ននេះ កម្មវិធីដែលព្រះសហគមន៍កំពុងតែធ្វើចំពោះជនរងគ្រោះ ដោយបន្ទុះជំងឺនេះនៅរកា គឺមានកម្មវិធីចុះសួរសុខទុក្ខនិងការចែកម្សៅទឹកដោះគោ ហើយកំពុងតែស្វែងរក ការគាំទ្រពីអង្គការបេសកកម្មកាតូលិកនៅអូស្ត្រាលី ដើម្បីអនុវត្តគម្រោងរយៈពេលវែងជាមួយនឹងបងប្អូនរងគ្រោះ ៕

**ដោយអរិយបុត្រ**

## ក្រសួងសុខាភិបាលជំរុញឲ្យពលរដ្ឋស្វែងរកសេវាសុខភាពផ្លូវការ

ក្រោយពេលដែលផ្ទុះករណីឆ្លងរីករាលជំងឺអេដស៍ នៅរកា ក្រសួងសុខាភិបាលបានជំរុញឲ្យ ប្រជាពលរដ្ឋទាំងអស់ ស្វែងរកសេវាសុខភាពនៅតាមមន្ទីរពេទ្យ មណ្ឌលសុខភាព និង សេវាសុខភាព ដែលមានការទទួលស្គាល់។

លោកស្រី សឿន សុភាត អនុប្រធានមណ្ឌលសុខភាពរកា បានមានប្រសាសន៍ថា នៅពេលដែលចុះមកសាកសួរសុខទុក្ខជនរងគ្រោះនៅរកានេះ ថ្នាក់ដឹកនាំក្រសួង គឺតែងតែជំរុញឲ្យពលរដ្ឋងាកមករកសេវាសុខភាពរដ្ឋដើម្បីសុវត្ថិភាព ។

លោកស្រីបានអះអាងថា សេវាសុខភាពដែលផ្តល់ដោយគ្រូពេទ្យវេជ្ជបណ្ឌិតដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ គឺមានក្រមសីលធម៌ច្បាស់លាស់នៅក្នុងការផ្តល់សេវាកម្មសុខភាព។

លោកស្រីបានបន្តទៀតថា បញ្ហានៅភូមិគឺជាឧទាហរណ៍ ដែលបញ្ជាក់ឲ្យប្រជាពលរដ្ឋត្រូវតែប្រយ័ត្ន ចំពោះប្រភពដែលផ្តល់សេវានៅពេលដែលព្យាយាមស្វែងរកសេវាកម្មនេះ៕

# លោកអភិបាល អូលីវីយេ ចូលរួមបុណ្យខួប១៥០ឆ្នាំ នៃការរកឃើញគ្រីស្តបរិស័ទ នៅទីក្រុងណាហ្គាសាគី



*លោកអភិបាលថតរូបអនុស្សាវរីយ៍ក្នុងឱកាសចូលរួមបុណ្យខួបទី១៥០ឆ្នាំ នៃការរកឃើញគ្រីស្តបរិស័ទ នៅទីក្រុងណាហ្គាសាគី ។រូបថត: សុធីរិទ្ធិ*

តាមការអញ្ជើញរបស់លោក យ៉ូសែប មីតស៊ូអាគី តាកាមី (Joseph MitsuakiTakami) ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគណាហ្គាសាគីប្រទេសជប៉ុន លោកអូលីវីយេ ជាអភិបាល នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ប្រទេសកម្ពុជា បានអញ្ជើញចូលរួមបុណ្យខួប១៥០ ឆ្នាំ នៃការរកឃើញគ្រីស្តបរិស័ទនៅទីក្រុងណាហ្គាសាគី ប្រទេសជប៉ុនកាលពីថ្ងៃទី ១៤ ដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០១៥កន្លងទៅ។

នៅក្នុងឱកាសនោះ លោកអភិបាល អូលីវីយេ ក៏បានទៅកន្លែងមួយចំនួនរបស់មរណសាក្សី នៃប្រទេសជប៉ុន ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់អំពីប្រវត្តិ នៃជំនឿរបស់មរណសាក្សីទាំងនោះ។ ពិធីបុណ្យយ៉ាងឱឡារិកបានប្រារព្ធនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ ២០១៥ ដើម្បីរំលឹកខួប១៥០ឆ្នាំ នៃការរកឃើញគ្រីស្តបរិស័ទ នៅទីក្រុងណាហ្គាសាគី គឺថ្ងៃ១៧ មីនា១៨៦៥-១៧ មីនា ២០១៥។ អង្គពិធីមានការអញ្ជើញចូលរួម ពីសំណាក់លោកអេមីនេន អូឡេនដូ បែលត្រាន់គេវេដូ (Eminence Orlando Beltran Quevedo) ជាកាឌីណាល់តំណាងសម្ដេចប៉ាប លោកអភិបាល លោកបូជាចារ្យមកពីប្រទេសផ្សេងៗ ជាច្រើនអង្គ រួមជាមួយនឹងតំណាងគ្រីស្តបរិស័ទ និងបរិស័ទសាសនាធំៗ នៅក្នុងប្រទេសជប៉ុន ប្រមាណជា ៥០០នាក់។

តាមប្រវត្តិសាស្ត្រ ប្រទេសជប៉ុនបានបិទទ្វារមិនឲ្យ មានជនបរទេសណាមួយ ចូលមកធ្វើជំនួញ ឬនាំសាសនាចូលក្នុងប្រទេសនេះ និងពិសេសមិនឲ្យប្រជាជនណាម្នាក់កាន់សាសនាគ្រីស្តជាដាច់ខាត អស់រយៈពេល២៥០ឆ្នាំ គឺពីឆ្នាំ១៦១០ ដល់ឆ្នាំ១៨៦០។ ក្នុងឆ្នាំ ១៨៦០ រដ្ឋាភិបាលជប៉ុនបានអនុញ្ញាតឲ្យសាងសង់ព្រះវិហារកាតូលិក ដើម្បីថ្វាយអភិបូជាសម្រាប់តែជនបរទេស ។ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៨៦៥ មានប្រជាជនជប៉ុនមួយក្រុម បានចូលក្នុងព្រះវិហារនោះ ហើយបានជួបបូជាចារ្យក្រោយមក ទើបគេដឹងថា ជាក្រុមគ្រីស្តបរិស័ទ ដែលបានបន្តជំនឿ ២៥០ឆ្នាំ ដោយឥតមានបូជាចារ្យ ឥតមានពិធីគោរពសាសនាអស់ ៧ ជំនាន់ គេបានធ្វើពិធីជ្រមុជទឹកឲ្យគ្នាទៅវិញទៅមក ក្នុងព្រះនាមព្រះបិតាព្រះបុត្រានិងព្រះវិញ្ញាណដ៏វិសុទ្ធ។ គេបានថែរក្សាជំនឿ ដោយចាំរបៀបប្រារព្ធពិធីជ្រមុជទឹក សូត្រធម៌ឱព្រះបិតា ធម៌ប្រកាសជំនឿ ធម៌បពិត្រព្រះនាងម៉ារីរយៈពេល២៥០ឆ្នាំតាំងពីជំនាន់ លោកបូជាចារ្យ ហ្វ្រង់ស្វ័រសាវីយេរហូតគេមានសេរីភាពប្រណិបត្តិសាសនាដូចបច្ចុប្បន្ននេះ៕

**ដោយសុធីរិទ្ធិ**



# បុណ្យហែស្លឹកឲ្យយើងចងចាំព្រះយេស៊ូរងទុក្ខលំបាក



*ពិធីហែស្លឹកនៅព្រះសហគមន៍ព្រះកុមារយេស៊ូ(បឹងទំពុន)។ រូបថតៈ លីហៀង*

គ្រីស្តបរិស័ទប្រមាណជាង ៣០០ នាក់ បានមកចូលរួមពិធី ហែស្លឹក ដែលជាពិធីរំឭកដល់ព្រះយេស៊ូយាងចូលក្រុង យេរូសាឡឹម ដើម្បីរងទុក្ខលំបាក ក្រោមអធិបតីភាពលោកអភិបាលភូមិភាគភ្នំពេញ អូលីវីយេ ឆ្មឹត អឺស្លែ កាលពីថ្ងៃទី២៩ មីនា នៅព្រះសហគមន៍កាតូលិកបឹងទំពុន នារាជធានីភ្នំពេញ។

លោកអភិបាល អូលីវីយេ មានប្រសាសន៍ថា ៖ ពិធីបុណ្យនេះគឺជាឱកាសមួយ ដែលយើងចូលរួមជាមួយព្រះយេស៊ូរងទុក្ខលំបាក និងសោយទិវង្គត។ លោកបន្តថា៖ ស្លឹកនេះតំណាងឲ្យការ គោរពជាព្រះមហាក្សត្រ និងធ្វើតាមអ្វីដែលពួកគេធ្លាប់ធ្វើកាលពីជាង ២០០០ឆ្នាំមុន និងក្រោយមកយើងទុកនៅផ្ទះដើម្បីនឹកឃើញបុណ្យនេះ ដែលជាបុណ្យនៃជីវិតដែលជួយយើងក្នុងមួយឆ្នាំឲ្យខិតខំកែប្រែចិត្តគំនិត កុំឲ្យយើងភ្លេច និងក្បត់ព្រះយេស៊ូដូចលោកយូដាស និង លែងស្គាល់ព្រះយេស៊ូដូចលោកសិលាពីដើម។

បងប្រុស ជួរ ដាម៉ូ ជានិស្សិតទេវវិទ្យាល័យ នៃក្រុមបព្វជិតសហជីវិនព្រះយេស៊ូ ដែលបានចូលរួមក្នុងកម្មវិធីនេះយល់ឃើញថា៖ ពិធីនេះរំឭកយើង ពីការទទួលព្រះយេស៊ូ ហើយដើម្បីទទួលព្រះអង្គ យាងចូលក្នុងខ្លួនយើង គឺយើងត្រូវទទួលស្គាល់ថាយើងជាមនុស្សទន់ខ្សោយ ដូចប្រជាជនសម័យនោះដែរ។ ដូចនេះយើងត្រូវមានមេត្តាធម៌ចំពោះខ្លួនឯង និងអ្នកដទៃផងដែរ។

លោកអភិបាល បានបន្តផ្តាំផ្ញើរដល់គ្រីស្តបរិស័ទទាំងអស់ ក្នុងឱកាសសប្តាហ៍ពិសិដ្ឋ ឲ្យចេះបម្រើគ្នា និងលើកលែងទោសឲ្យគ្នាទៅវិញទៅមក ដូចព្រះយេស៊ូ លាងជើងឲ្យក្រុមសាវ័ក និង លើកលែងទោសឲ្យអ្នកដែលសម្លាប់ព្រះអង្គនៅលើឈើឆ្កាង ។ ជាពិសេស យប់បុណ្យចម្លងខាងមុខយើងទទួលស្វាគមន៍ គ្រីស្តបរិស័ទថ្មី ១៦០នាក់ នៅក្នុងភូមិភាគភ្នំពេញ យើងទទួលពិធីជ្រមុជទឹក ជាឱកាសមួយ ដើម្បីទទួលស្គាល់ថា ពិតមែនព្រះយេស៊ូជាជីវិត ឲ្យយើងទៅជាមនុស្សថ្មី ដោយចេះសម្តែងមេត្តាករុណាគ្រប់កាលៈទេសៈនៅក្នុងជីវិតរបស់យើង៕

**ដោយដាលីស**

# លោករឿង ផ័ត្រសិរី ដឹកនាំក្រុមសង្គហៈចុះសួរសុខទុក្ខអ្នកស្វែងរកជំនឿ

លោកបូជាចារ្យ រឿង ផ័ត្រសិរី បានដឹកនាំក្រុមសង្គហៈនៃព្រះវិហារសន្តីម៉ារីម៉ាដាឡា (គីឡូម៉ែតលេខ ១១) ចំនួន៦នាក់ ដើម្បីទៅសួរសុខទុក្ខ និង លើកទឹកចិត្តដល់អ្នកស្រី មាស វណ្ណី ជាស្ត្រីមេម៉ាយដែលសព្វថ្ងៃនេះកំពុងចង់ស្វែងយល់អំពីជំនឿជាគ្រីស្តបរិស័ទកាតូលិកកាលពីថ្ងៃទី ២២ មីនាកន្លងទៅ។

លោកបូជាចារ្យ ផ័ត្រសិរី ឲ្យដឹងថា ការចុះមកសួរសុខទុក្ខនេះ គឺមានគោលបំណង ចង់លើកទឹកចិត្តដល់អ្នកស្រី វណ្ណី ដែលកំពុងតែមានចិត្តចង់ស្វែងយល់អំពីជំនឿជាកាតូលិក។ លោកបានឲ្យដឹងថា លោកនិងក្រុមសង្គហៈ បានជួបអ្នកស្រីបាន ២ដងរួចមកហើយ ប្រមាណជាប៉ុន្មានខែមុន ដោយសារអ្នកស្រីបានទៅដល់ព្រះវិហារ និង បានសួរនាំអំពីជំនឿខ្លះៗ។

អ្នកស្រី មាស វណ្ណី អាយុ៤៨ឆ្នាំ បានឲ្យដឹងដែរថា អ្នកស្រីកន្លងមកនឹកឃើញ អំពីការជួយរបស់ក្រុមអង្គការកាតូលិកសុីអរអេស (Catholic Relief Service) ដែលបានជួយដល់អ្នកស្រីតាំងពីនៅក្នុងជំរុំខ្មែរថៃ។កាលនៅជំរុំ អ្នកស្រី ធ្លាប់បានសិក្សាវគ្គខ្លីអំពីការព្យាបាលជំងឺ ជាមួយអង្គការសុីអរអេស រហូតមកដល់ពេលនេះ អ្នកស្រីបានក្លាយជាគ្រូពេទ្យម្នាក់នៅក្នុងរោងចក្រកាត់ដេរមួយ។ អ្នកស្រី វណ្ណី សព្វថ្ងៃនេះ ទទួលបន្ទុកចិញ្ចឹមកូនប្រុសស្រី២នាក់។ អ្នកស្រីវណ្ណី "ចេះតែនឹកឃើញថា ពីមុនបានទៅរកព្រះយេស៊ូដើម្បីរៀនសូត្រ ដូចជាមានអារម្មណ៍មានព្រះយេស៊ូ តាមជួយរហូត ហើយគិតថាបើវិលទៅរកព្រះយេស៊ូវិញក៏ល្អដែរ"។



*លោកបូជាចារ្យ រឿង ផ័ត្រសិរី ប្រគល់អំណោយដល់បងស្រីមាស វណ្ណី ដែលកំពុងតែចង់ស្វែងយល់ពីជំនឿជាគ្រីស្តបរិស័ទ។ រូបថតៈកញ្ញា*

លោកបូជាចារ្យ ផ័ត្រសិរី បានឲ្យដឹងទៀតថា លោកនឹងរកពេលវេលាក្នុងមួយខែម្តង មកអប់រំជំនឿអ្នកស្រីដល់ផ្ទះ ព្រោះផ្ទះរបស់គាត់នៅឆ្ងាយពីព្រះវិហារសន្ត ម៉ារីម៉ាដាឡា ប្រមាណជាង៤០គីឡូម៉ែតឯណោះ ។ ហើយអ្នកស្រីទៀតសោធ ក៏គ្មានយានជំនិះផ្ទាល់ខ្លួនដែរ។

ជាមួយនឹង ការសួរសុខទុក្ខនេះ ក្រុមសង្គហៈ ក៏មានអង្ករប្រមាណ៥គីឡូជូនដល់អ្នកស្រីផងដែរ៕

**ដោយកញ្ញា**

# ពេទ្យឃាយជីរួមចំណែកព្យាបាលជំងឺសរសៃនៅកម្ពុជា



*រូបភាពសកម្មភាពអ្នកជំងឺដែលកំពុងធ្វើការសំរាកព្យាបាលនៅពេទ្យឃាយជី ។រូបថតៈសុវណ្ណា*

ពេទ្យឃាយជី ដែលពលរដ្ឋទូទៅនៅក្នុងទីក្រុង បាត់ដំបងដឹងថា គឺជាមន្ទីរពេទ្យនៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង នៅតែបន្តរួមចំណែកយ៉ាងស្វាហាប់ នៅក្នុងការចូលរួមជួយវិស័យសុខាភិបាល នៅក្នុងប្រទេស ។

នៅក្នុងចំណោម សេវាកម្មសុខភាពមនុស្សធម៌ជាច្រើនផ្នែក ដែលមន្ទីរពេទ្យឃាយជីបានផ្ដល់ឲ្យ ដល់ពលរដ្ឋទូទៅ ពិសេសគឺពលរដ្ឋក្រីក្រជំងឺសរសៃ គឺជាសេវាកម្មមនុស្សធម៌មួយដែលមន្ទីរពេទ្យនេះកំពុងតែផ្ដល់ដល់ជនដែលរងគ្រោះទាំងឡាយ ។

បងស្រីម៉ារីចន្ទអ្នកទទួលខុសត្រូវផ្នែកជំងឺសរសៃនៅមន្ទីរពេទ្យឃាយជីបានមានប្រសាសន៍ថា សេវាកម្មព្យាបាលជំងឺសរសៃនេះ ត្រូវបានបើកផ្ដល់ជូនពលរដ្ឋកម្ពុជា កាលពី៣ឆ្នាំមុន នៅឃុំឈើទាល សុក្របាណន់ ហើយក្រោយមក ដោយសារតែតំរូវការនូវការសង្គ្រោះនេះ មានការកើនឡើង មន្ទីរពេទ្យឃាយជី ក៏បានបើកសេវាកម្មនេះមួយកន្លែងទៀតនៅនឹងពេទ្យឃាយជីផ្ទាល់ នៅក្នុងទីក្រុងបាត់ដំបងនេះផ្ទាល់។

បងស្រីបានបញ្ជាក់ថា "ទាំងនៅឈើទាល និង មន្ទីរពេទ្យឃាយជីយើងអាចមានលទ្ធភាព ទទួលអ្នកជំងឺ ប្រហែលជា ៣០នាក់នៅក្នុងមួយថ្ងៃ "។

បងស្រីបានឲ្យដឹងថា ពេទ្យឃាយជីដែលជាមណ្ឌលសុខភាពមួយ នៅបាត់ដំបង យើងមានយូរហើយ ប៉ុន្តែជំនាញព្យាបាលសរសៃនេះ គឺចេញមក ពីការដែលបងស្រីបានឃើញនៅតាមភូមិមានអ្នកជំងឺឈឺសរសៃច្រើន ហើយពួកគេក្រីក្រ ដូច្នេះបងស្រី ក៏បានសុំលោកអភិបាល បើកកន្លែងព្យាបាលមួយ នៅឈើទាល ដែលមានចំងាយ ប្រហែលជា ១២គ.ម។ កាលពីបីឆ្នាំមុន នៅទីនោះ គឺមានអ្នកជំងឺច្រើន គឺខ្លះមកពី បាត់ដំបងពីបាណន់ និងខេត្តឆ្ងាយ ក៏មានអ្នកជំងឺមក ប៉ុន្តែដោយទៅទីនោះកន្លែងវាតូច ដូច្នេះក៏បងស្រី ក៏បានសំរេចស្នើសុំលោកអភិបាលបើកនៅកន្លែងពេទ្យឃាយជីនេះបន្ថែមទៀត ។

បងស្រីបានឲ្យដឹងថា នៅពេទ្យឃាយជី យើងបានបើកសេវាកម្មព្យាបាលសរសៃនេះ កាលពីខែឧសភាឆ្នាំ២០១៤ ដោយអ្នកជំងឺមកពីបាត់ដំបង និង ខេត្តផ្សេងៗ គឺមកទីនេះ ហើយអ្នកជំងឺនៅបាណន់ និង ឈើទាល គឺនៅមន្ទីរពេទ្យឯឈើទាល ។

តាមប្រសាសន៍របស់បងស្រី អ្នកជំងឺធម្មតាដូចជា ឈឺស្មា ចុករោយអី គឺត្រូវការព្យាបាលនៅទីនេះប្រមាណជា១ សប្ដាហ៍ ឬ ២ សប្ដាហ៍ ប៉ុន្តែសម្រាប់អ្នកដែល ងាប់មួយចំហៀងខ្លួន គឺអាចព្យាបាលនៅទីនេះ ប្រហែលជា ៣ខែ លើសពីនេះ ដោយអ្នកជំងឺ មិនមានចំណាយអ្វីទាំងអស់ ហើយអត់មានការរើសអើងអ្វីឡើយ ។

បងស្រីបានឲ្យដឹងថា នៅពេទ្យឃាយជីនេះ គឺយើងបើកពីម៉ោង ៧:-៣០នាទី ដល់ម៉ោង១១:៣០ ដោយនៅក្នុងពេលដែល អ្នកជំងឺមករកសេវានៅទៅនេះ គឺពួកគេដំបូង គឺត្រូវហាត់ប្រាណរាល់ពេលមកដល់ ជាមួយនឹងឧបករណ៍ដែលយើងមាន ហើយបន្ទាប់មកគឺធ្វើសរសៃ មួយសប្ដាហ៍បាន៣ដង ហើយគេនឹងទទួលការចាក់ម្ជុលវិទ្យាសាស្ត្រ ហើយបើគេទំនេរអ្នកជំងឺអាចមក ហាត់ប្រាណនៅទីនេះរាល់ថ្ងៃក៏បាន ។

បងស្រីបានបន្តទៀតថា ដោយសារតែទីនេះ តំរូវការអ្នកជំងឺមានការកើនឡើង បងស្រីមានគម្រោងការរៀបចំស្នើសុំបន្ថែមសម្ភារ។

បងស្រីបានឲ្យដឹងថានៅពេលនេះ មន្ទីរពេទ្យមាន មានបុគ្គលិកទាំងអស់ ៧នាក់ ដោយអ្នកដែលមានជំនាញពេទ្យបុរាណ គឺមាន២នាក់ ដោយឡែក អ្នកដែលស្ម័គ្រចិត្តចង់រៀន គឺយើងអាចបង្រៀននៅមន្ទីរពេទ្យឃាយជី ក្រៅពីនេះ យើងមានបងស្រីមកពីកូរ៉េ មកពីថៃ គាត់មកទស្សនកិច្ច និងមកជួយយើងផងដែរ ។

រហូតមកដល់ពេលនេះ អ្នកជំងឺនៅទីនេះគឺមានសុទ្ធតែអ្នកដែលពិការ គឺ ខ្លះជើង ខ្លះដៃ ខ្លះរៀចមាត់ ហើយអ្នកដែលធម្មតា គឺមានតិចណាស់ ។ ឧបករណ៍ដែលមានបំពាក់នៅកន្លែងព្យាបាលសរសៃនេះ គឺមានឧបករណ៍ជាក់កង់ ជួយក្បាលជង្គង់ ឧបករណ៍យោលជើង ដើម្បីពង្រឹងសាច់ដុំជើង ហើយក៏មានឧបករណ៍ រុញដោយដៃ ដើម្បីឲ្យស្មាប្រសើរ យើងក៏មានឧបករណ៍គ្រវីដៃ និងឧបករណ៍ផ្សេងៗទៀត ដែលឧបករណ៍ទាំងនេះ គឺសម្រាប់អ្នក ដែលងាប់មួយចំហៀងខ្លួន ។

បងស្រី ម៉ារី ចន្ទ បានមានប្រសាសន៍ថា បន្ទាប់ពីហាត់ប្រាណ គឺអ្នកជំងឺមានឱកាសធ្វើសរសៃ ហើយនិង ចាក់ម្ជុលវិទ្យាសាស្ត្រ ហើយអ្នកខ្លះ ដែលខ្លាចម្ជុលវិទ្យាសាស្ត្រ គឺមន្ទីរពេទ្យមានវិធីស្អំសាច់ដុំ និង ស្អំសរសៃជូនគាត់។

បងស្រីបានមានប្រសាសន៍ថា ដើម្បីកាត់បន្ថយ ហានិភ័យអំពីជំងឺសរសៃរនេះ គឺទាំងអស់គ្នាត្រូវតែធ្វើការហាត់ប្រាណ។

លោក ឈួន ឌឿន អាយុ ៤៨ ឆ្នាំ ដែលមានទីលំនៅបាត់ដំបង ដែលបានកំពុងតែព្យាបាលនៅទីនេះ បានមានប្រសាសន៍ថា ដំបូងគាត់បានមកព្យាបាលនៅទីនេះ ដោយពិការមួយចំហៀងខ្លួន ពោលគឺលើកដៃលើកជើងមិនកើត ប៉ុន្តែក្រោយពេលដែលព្យាបាលនៅទីនេះ បាន ៤ ខែ លោកអាចងើបដើរបាន ។

លោកបានបញ្ជាក់ថា "ទោះបីកាលនោះ ខ្ញុំដើរដោយឈើច្រត់ តែខ្ញុំពិតជាសប្បាយចិត្ត កាលនោះហើយមកដល់ពេលនេះវារឹតតែប្រសើរ ដោយខ្ញុំអាចគ្រវាត់ចោលឈើច្រត់ ដើរដោយខ្លួនខ្ញុំថែមទៀត គ្រាន់តែមិនដូចកាលជាក៏ដោយចុះ"។

លោក ឈួន ឌឿន នៅពេលនេះ គឺកំពុងតែបន្តទទួលសេវាកម្មព្យាបាលនៅមន្ទីរពេទ្យឃាយជីដដែល ដោយគិតចាប់តាំងពីពេលនោះ មកដល់ពេលនេះគឺ បាន៧ខែហើយ ។

លោក ខាត់ សារី អាយុ ៥៩ ឆ្នាំ មកពីខេត្តបន្ទាយមានជ័យ បានមានប្រសាសន៍ថា គាត់បានឈឺដោយជំងឺលើសឈាម នេះកាលពីពាក់កណ្ដាលខែកុម្ភៈ ដោយពិការដៃ និងជើង ហើយនិយាយមិនចេញតែពេលនេះអាចនិយាយចេញ ហើយដៃជើងគឺអាចកម្រើកបានខ្លះៗហើយ ។

លោកស្រី សាំង សារី អាយុ ៦៣ ឆ្នាំ បានមានប្រសាសន៍ថា នៅពេលនេះលោកស្រីនិងស្វាមី គឺកំពុងតែព្យាបាល នៅមន្ទីរពេទ្យនេះទាំងពីរនាក់ប្ដីប្រពន្ធ។ លោកស្រី បានឲ្យដឹងថាលោកស្រីមិនទាន់ធ្ងន់ធ្ងរទេ ដោយគ្រាន់តែវិលៗម្ដង ប៉ុន្តែបើស្វាមីលោកស្រី គឺពិការតែម្ដង ហើយពេលនេះបងស្រីកំពុងតែព្យាបាល៕

**ដោយ អាយុវន្ត**

# ប្រជុំវាយតម្លៃនិងរៀបចំផែនការឆ្នាំ២០១៥នៃសមាគមសន្តវ៉ាំងសង់ដឺប៉ូលកម្ពុជា




*ក្រុមសន្តវ៉ាំងសង់ដឺប៉ូលថតរូបអនុស្សាវរីយ៍ពេលប្រជុំវាយតម្លៃនិងរៀបចំផែនការសម្រាប់ឆ្នាំ២០១៥។ រូបថតៈ រ៉ាវី*

ក្រុមប្រឹក្សាថ្នាក់ជាតិ ព្រមទាំងប្រធានក្រុម និងអនុប្រធានក្រុម នៃសមាគមសន្តវ៉ាំងសង់ដឺប៉ូល ក្នុងប្រទេសកម្ពុជាប្រមាណជិត ២០នាក់ បានរៀបចំការប្រជុំមួយដែលប្រព្រឹត្តទៅកាលពីថ្ងៃទី៨ និង ៩ ខែមីនា នៅព្រះសហគមន៍កំពង់ចាម ដែលមានវត្តមានបើកអង្គប្រជុំស្វាគមន៍ ដោយលោកឪពុក ហ្វ្រង់ស័រ អេមេដាល្ស និងវត្តមានលោកអភិបាល អន់តូនីសាមីស៊ូសៃរាជ្យ ជាអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម។

លោកអភិបាល អន់តូនី មានប្រសាសន៍ថា ការចុះសួរសុខទុក្ខអ្នកក្រីក្រ ជាសកម្មភាពដ៏ប្រសើរ ដើម្បីជួយឲ្យសមាជិក នៃក្រុមនីមួយៗ ស្គាល់ ពីទុក្ខលំបាករបស់អ្នកក្រីក្រ ហើយទោះបីជាទាំងថវិកា និងសម្ភារដើម្បីជួយអ្នកទាំងនោះមានលក្ខណៈស្តួចស្តើង តែវាជាកំលាំងមួយ ដែលចូលរួមជាមួយព្រះសហគមន៍ ដើម្បីបម្រើអ្នកក្រីក្រដែរ ។ ជាចុងបញ្ចប់ លោកអភិបាល ក៏បានអរគុណដល់សមាជិកទាំងអស់ដែលបានស្ម័គ្រចិត្តចូលរួមសហការ ជាមួយព្រះសហគមន៍ដើម្បីបម្រើអ្នកក្រីក្រ។

លោក ផាន ប៉ូរ៉ា ជាប្រធានក្រុមប្រឹក្សាថ្នាក់ជាតិ ប្រទេសកម្ពុជាមានប្រសាសន៍ថា គោលបំណង នៃការប្រជុំនេះគឺធ្វើឡើង ដើម្បីធ្វើការវាយតម្លៃទៅលើសកម្មភាពក្នុងឆ្នាំ២០១៤ ដើម្បីដាក់ផែនការអនុវត្តន៍ ក្នុងឆ្នាំ ២០១៥ ឲ្យចំនឹងទិសដៅ នៃសមាគម ជាពិសេសគឺធ្វើយ៉ាងណាឲ្យការដឹកនាំសកម្មភាពតាមក្រុមនីមួយៗកាន់តែមានប្រសិទ្ធភាព ពោលគឺចូលរួមសហការជាមួយ ព្រះសហគមន៍ ដើម្បីជួយបម្រើអ្នកក្រីក្រ ដែលត្រូវការជំនួយ និងដើម្បីជាការបង្ហាញនូវការយកចិត្តទុកដាក់ ក្នុងជីវិតរបស់ពួកគេ។

លោកប៉ូរ៉ា ឲ្យដឹងទៀតថា ក្នុងឆ្នាំនេះសមាគមរបស់យើង នឹងបង្កើនគម្រោងផ្តល់អាហារូបករណ៍ ដល់សិស្ស រៀននៅកម្រិតចំណេះដឹងទូទៅបន្ថែម និងផ្តល់ជំនួយដល់ប្រជនក្នុងតំបន់នូវសម្ភារផ្ទះ ទឹកស្អាត បង្គន់អនាម័យជាដើម ទៅតាមតម្រូវនៃកន្លែងនីមួយៗតាមថវិកាដែលទទួលបានពីម្ចាស់ជំនួយ។

លោក ធឹម ធន់ ជាតំណាងយុវជននៃសមាគមន៍សន្តវ៉ាំងសង់ដឺប៉ូល ក្នុងប្រទេសកម្ពុជាឲ្យដឹងថា ការប្រជុំនេះធ្វើឲ្យ ក្រុមប្រឹក្សាថ្នាក់ជាតិយើងបានដឹងពីបញ្ហា ដែលកើតមានក្នុងក្រុមនីមួយៗ យើងចែកបទពិសោធន៍សម្រាប់ក្រុមនីមួយៗ ដូចជាសកម្មភាពចុះសួរសុខទុក្ខអ្នកក្រីក្រ កម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងការធ្វើគម្រោងថ្មីជាដើម ដែលឆ្លើយតបទៅនិងដៃគូ ដែលបានគាំទ្រក្រុម ក្នុងគោលបំណងឲ្យមានទំនាក់ទំនងនឹងមានធម៌មេត្តាករុណាចំពោះអ្នកដទៃ។ ហើយឲ្យយើងលើកទឹកចិត្តពួកគាត់ បន្តសកម្មភាពបម្រើអ្នកក្រីក្រដោយរួមសហការ ជាមួយព្រះសហគមន៍បន្ថែមទៀត៕

**ដោយសុខឃីម**

# កិច្ចសហការដើម្បីជួយកុមារក្រីក្រឲ្យបានទទួលការសិក្សា

ព្រះសហគមន៍ កាតូលិកកំពង់-ចាមក្រុង និង អង្គការកុមារមេគង្គកម្ពុជាបានជួបប្រជុំគ្នាដើម្បី ពង្រឹងការទទួលខុសត្រូវ និងការចាត់ចែងផ្នែកហិរញ្ញវត្ថុតាម តំបន់នីមួយៗធ្វើឡើងកាលពីថ្ងៃ ទី២០ មីនា នៅព្រះ-សហគកមន៍កាតូលិក កំពង់ចាមក្រុង ស្ថិតនៅភូមិទី១ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

លោក ហ្សាល វីលយ៉ង់គួ ( CharlesWilliencourt ) ជាអ្នកស្ម័គ្រចិត្តម្នាក់មកពីមកពីប្រទេសបារាំង និងជាអ្នកទទួលខុសត្រូវតំបន់ បានមានប្រសាសន៍ថា៖ អង្គការកុមារមេគង្គមានបំណងចង់ឲ្យស្ថាប័នជាដៃគូចេះអំពីរបៀបនៃការ ទំនាក់ទំនងជាមួយកុមារ និង ស្គាល់អំពីគោលដៅរបស់អង្គការកុមារមេគង្គច្បាស់ ជាងមុន ហើយយើងក៏បង្រៀន អំពីរបៀបធ្វើគណនេយ្យផងដែរ។

លោក ហ្សាលវីលយ៉ង់គួ បន្តថា សព្វថ្ងៃនេះ អង្គការកុមារមេគង្គមានទំនាក់ទំនង ជាមួយព្រះសហគមន៍-កាតូលិក ដើម្បីជួយដល់កុមារក្រីក្រឲ្យបានរៀនសូត្រ នៅតំបន់កំពង់ចាមមានចំនួន ៩ព្រះសហគមន៍ ដូចជាមេមត់ កំពង់ចាមក្រុង រលៀក មណ្ឌលស្នាក់នៅកំពង់ចាមក្រុង( សិស្សប្រុស និងស្រី ) កោះរកា ក្តុលលើ អណ្តូងច្រុះ និង ថ្មពេជ្រ ហើយអង្គការនេះ



*លោក ហ្សាល វីលយ៉ង់គួ បានដឹកនាំការជួបជុំគ្នាក្នុងកិច្ចសហការដើម្បីជួយកុមារក្រីក្រឲ្យបានទទួលការសិក្សា ។រូបថតៈ រ៉ាវី*

ក៏មានទំនាក់ទំនង ជាមួយព្រះសហគមន៍នៅខេត្តកំពង់ធំផងដែរ ៕ **ដោយរ៉ាវី**

# ទស្សនកិច្ចរបស់បងស្រីតេរេស៊ីតា នៅសាលាបឋមសិក្សាដុនបូស្កូព្រែក

បងស្រី តេរេស៊ីតា ហ្គាស្យា ជាបងស្រីប្រធានក្រុមគ្រួសារ ព្រះនាងម៉ារីជាទីពំនឹងនៅកម្ពុជា និងភូមា បានធ្វើការសំណេះសំណាលជាមួយសិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ នៅសាលាបឋមសិក្សា ដុនបូស្កូព្រែស កាលពីថ្ងៃទី២០ ខែមីនាកន្លងទៅ។

ក្នុងកម្មវិធីនោះបងស្រី បានលើកទឹកចិត្តនិង ផ្តាំផ្ញើដល់សិស្សទាំងអស់ឲ្យខិតខំរៀនសូត្រ កសាងខ្លួនឲ្យល្អសម្រាប់អនាគត ត្រូវចេះស្តាប់បង្គាប់លោកគ្រូ និងអ្នកគ្រូ និងស្តាប់បង្គាប់ឪពុកម្តាយ។ ក្នុងនោះផងដែរ បងស្រីក៏បានថ្លែងអំណរគុណ និងកោតសរសើរ ដល់លោកគ្រូអ្នកគ្រូ ដែលបានខិតខំយកចិត្តទុកដាក់ បង្រៀន និងបំពេញតួនាទីបានយ៉ាងល្អ ក្នុងការអប់រំសិស្ស ឲ្យមានវិន័យល្អពីមួយឆ្នាំទៅមួយឆ្នាំ។

សាលាបឋមសិក្សាដុនបូស្កូព្រែស គ្រប់គ្រង ដោយក្រុមគ្រួសារព្រះនាងម៉ារី ជាទីពំនឹង នៅកម្ពុជា។

ក្រុមគ្រួសារ ព្រះនាងម៉ារី ជាទីពំនឹងនៅកម្ពុជា មកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩២ ដោយមានបេសកកម្មក្នុងផ្នែកអប់រំ។ ក្រុមបងស្រីមានសាលារៀនដូចជា មត្តេយ្យសិក្សា បឋមសិក្សា និងវិទ្យាល័យ ដែលមានទីតាំងនៅភ្នំពេញ និងបាត់ដំបង៕

**ដោយម៉ូន អេង**

# គ្រូអប់រំជំនឿសំណាក់ធម៌រិះគិតពីឆ្នាំមេត្តាករុណា

ក្រុមគ្រូអប់រំជំនឿ នៃមណ្ឌលសកម្មភាពតាខ្មៅ រួមជាមួយក្រុមគ្រូអប់រំជំនឿ នៃព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន សរុបចំនួន១២នាក់បានជួបជុំគ្នារិះគិត ពីឆ្នាំមេត្តាករុណា ក្រោមប្រធានបទ "តើនរណាជាបងប្អូនខ្ញុំ?"។ ពិធីសំណាក់ធម៌នេះ ប្រព្រឹត្តទៅកាលពីថ្ងៃទី១៥ខែមីនាឆ្នាំ២០១៥កន្លងទៅនេះ នៅមណ្ឌលសកម្មភាពតាខ្មៅ ណែនាំដោយលោក វ៉ាំងសង់ សីនេយ៍ឆាល់ ជាបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាព ភ្នំពេញខាងត្បូង។

ពិធីសំណាក់ធម៌ បានរិះគិតអំពីកាលើកលែងទោស និងអំពីការស្រឡាញ់ខ្មាំងសត្រូវរបស់ខ្លួន ឲ្យអ្នកចូលរួមចេះបង្ហាញធម៌មេត្តាករុណាចំពោះមនុស្សទាំងអស់។

លោកបូជាចារ្យ វ៉ាំងសង់ សីនេយ៍ឆាល់ មានប្រសាសន៍ថា៖ ជាគ្រូអប់រំជំនឿ មិនមែនដូចជាគ្រូដែលបង្រៀន ចំណេះវិជ្ជាទូទៅ នៅសាលានោះទេ តែយើងប្រៀបដូចជាបងដែលណែនាំប្អូន ឲ្យស្គាល់ព្រះជាម្ចាស់។ ប្អូនទាំងនោះ គឺជាព្រះអំណោយទាន ដែលមកពីព្រះជាម្ចាស់ គឺជាបងប្អូនដែលព្រះជាម្ចាស់ប្រទានមកយើង។ ហើយយើង គឺគ្មានសិទ្ធិ សម្រេចចិត្តជ្រើសរើសដោយខ្លួនឯងថា នរណាជាបងប្អូនរបស់ខ្លួននោះទេ៕

**ដោយ សុធា ម៉េងហ៊ៃ**

# យុវជនប្រាំប្រទេសរួមគ្នារិះគិតអំពីជីវិតផ្លូវវិញ្ញាណនិងការជួយដល់សង្គមជាតិ



*យុវជនបំបែកជាក្រុមតូចៗចែករំលែកអំពីព្រះបន្ទូល។ រូបថតៈដាលីស*

យុវជនគ្រីស្តបរិស័ទ កាតូលិក ប្រមាណ ១១៥នាក់ មកពីប្រទេសចំនួន៥ បានមកជួបជុំគ្នាក្នុងមណ្ឌលសកម្មភាពភ្នំពេញថ្មី ស្ថិតនៅភូមិព្រែស សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ នាថ្ងៃទី៣ រហូតដល់ទី៧ មីនា២០១៥នេះ ដើម្បីធ្វើពិធីសំណាក់ធម៌រួមមួយ អំពីរបៀបនៃការទំនាក់ទំនង និងបង្កើតសន្តិភាពរវាងប្រជាជាតិអាស៊ាន។

លោកផុន សុផល ជាអ្នកទទួលត្រូវកម្មវិធីនេះ បានឲ្យដឹងថា៖ ក្នុងកម្មវិធីនេះ យើងមានប្រធានបទ "ដើម្បី ឲ្យយើងក្លាយជាអំបិលសម្រាប់ពិភពលោក"។ ហើយគោលដៅសំខាន់នៃកម្មវិធីនេះ គឺដើម្បីឲ្យយុវជនអាចស្គាល់គ្នាទៅវិញទៅមកនិងចាប់ផ្តើមរិះគិត ពីជីវិតខាងវិញ្ញាណជាគ្រីស្តបរិស័ទរួមគ្នា ដែលមានប្រទេសចំនួន៥ដូចជា កម្ពុជា ឡាវ វៀតណាម ថៃ និងមីយ៉ានម៉ា។ យើងឲ្យពួកគាត់រិះគិតរួមគ្នា អំពីរបៀបសម្រុះសម្រួលគ្នា របៀបកសាងសន្តិភាព និងការកសាងព្រះសហគមន៍ជាលក្ខណៈអាស៊ាន។

កម្មវិធីសំណាក់ធម៌នេះ បានធ្វើឡើងដោយមានការរៀបចំពីការិយាល័យ យុវជនព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ នាប្រទេសកម្ពុជាដោយមានការសហការពីសហគមន៍តេហ្សេ ពីប្រទេសបារាំងណែនាំ និងមានអធិដ្ឋាន តាមបែបតេហ្សេដោយបងប្រុស ហ្គីលឡាំង(Ghislain)និងបងប្រុស អាន់ ឡេៀ (Andrea)។

បងប្រុសអាន់ ឡេៀ ជាអ្នករៀបចំ និង ណែនាំកម្មវិធីនេះ បានមានប្រសាសន៍ថា៖ ការអធិដ្ឋានដោយស្ងៀមស្ងាត់ គឺបានជួយដល់ពួកគេក្នុងការទំនាក់ទំនងជាមួយព្រះជាម្ចាស់ ។ លោកបន្ថែមថា៖ "ខ្ញុំមានអារម្មណ៍យល់ថា យុវជនទាំងនោះពិតជាយល់យ៉ាងច្បាស់ថា ពួកគេគឺជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ហើយសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ តែងតែដឹកនាំយើង និងព្រះជាម្ចាស់បានត្រាស់ហៅយើងឲ្យនាំ សេចក្តីស្រឡាញ់នោះទៅឲ្យអ្នកដែលនៅជុំវិញ។ ហើយខ្ញុំសង្ឃឹមថា ពេលពួកគេត្រលប់ទៅវិញ នឹងធ្វើជាសក្ខីភាព អំពីសេចក្តីស្រឡាញ់មួយនេះ តាមរយៈការអធិដ្ឋាន និង របៀបរស់នៅប្រចាំថ្ងៃ ដោយតាំងចិត្តចែករំលែកដល់អ្នកជុំវិញជាពិសេសជាមួយអ្នកក្រីក្រ។

កម្មវិធីនេះ មានការិះគិតពីប្រធានបទនីមួយៗ ដែលមានការណែនាំដោយបងប្រុស Andreas តាមរយៈព្រះបន្ទូលដោយ ស្មឹងស្មាធិ៍ផ្ទាល់ខ្លួនមួយថ្ងៃ២ដង និងចែករំលែកយោបល់ក៏ដូចជាបទពិសោធន៍ផ្ទាល់ របស់យុវជនម្នាក់ៗតាមក្រុម និង តាមប្រធានបទនីមួយៗ។ជាពិសេសបានផ្តល់ពេលវេលា ឲ្យយុវជនអធិដ្ឋានចំនួន៣ដងក្នុងមួយថ្ងៃ ដើម្បីជួយឲ្យយុវជនទាំងនោះ មានបទពិសោធន៍បន្ថែមទៀតចំពោះជីវិត ខាងផ្លូវវិញ្ញាណ ដោយចេះកោតសរសើរ និងសន្ទនាជាមួយព្រះជាម្ចាស់ តាមរយៈចម្រៀងផងដែរ។

ក្នុងថ្ងៃបិទពិធីសំណាក់ធម៌ លោកអភិបាលអូលីវីយេ ឝ្មឹតអី ស្មែ បានមានប្រសាសន៍ក្នុងធម្មទេសនា ក្នុងមួយសប្តាហ៍នេះបងប្អូនជាយុវជនបានរិះគិតច្រើនអំពីផ្លូវវិញ្ញាណ និងសង្គម។ លោកបន្តថា នៅចុងឆ្នាំ២០១៥ខាងមុខនេះ ប្រទេសក្នុងតំបន់អាស៊ានទាំង១០ នឹងបញ្ចូលគ្នាជាសមាហរណកម្មមួយ ខាងផ្នែកសេដ្ឋកិច្ច។ ហើយយើងឮច្រើនអំពី សេដ្ឋកិច្ចទីផ្សារនិងអាជីវកម្ម។លោកអភិបាលបានសំណូមពរដល់យុវជន គ្រីស្តបរិស័ទ ឲ្យខិតខំយកចិត្តទុកដាក់បន្ថែមទៀត ទៅលើការជួយដល់ជនក្រីក្រ ដើម្បីឲ្យគេមានកន្លែងមួយនៅក្នុងសង្គម ដោយមានកិត្តិយសទទួលតម្លៃនៃជីវិត មានសិទ្ធិសេរីភាពមានជីវិតខាងផ្លូវវិញ្ញាណបរិបូរណ៍និងឲ្យគេមានសុភមង្គល៕

**ដាលីស**

# មន្ទីរពេទ្យព្រះកុមារយេស៊ូលើកកម្ពស់សុខភាពកុមារលើវិស័យសុខាភិបាល




*ស្ត្រីជាម្តាយនាំកូនមកសម្រាកព្យាបាលនៅមន្ទីរពេទ្យព្រះកុមារយេស៊ូ។ លីហៀង*

មន្ទីរពេទ្យព្រះកុមារយេស៊ូ នៃសន្តអាសនៈ ដែលមានទីតាំងនៅក្នុងខេត្តតាកែវ មានសេវាកម្មទទួលកុមារគ្រប់ស្រទាប់វណ្ណៈទាំងអស់ និងពីគ្រប់ទីកន្លែងដើម្បីមកពិនិត្យ និងព្យាបាលជំងឺ ដោយសហការណ៍ជាមួយ មន្ទីរពេទ្យបង្អែកខេត្តតាកែវ។ សេវាកម្មទាំងនោះ បានជួយដល់កុមារជាច្រើន ពាន់នាក់ ក្នុងមួយឆ្នាំៗ។

កំពុងជជែកជាមួយអ្នកសម្រាករួមក្នុងបន្ទប់ សម្រាកព្យាបាលអ្នកជំងឺ អ្នកស្រីផាន់ ញ៉ៅ មកមើលថែរក្សាកូនប្រុសរបស់គាត់ ជាង១សប្តាហ៍មកហើយ។ អ្នកស្រីបានឲ្យដឹងថា គាត់បានយកកូនប្រុស អាយុ១៨ឆ្នាំមកវះកាត់ដៃជាប់នឹងក។ អ្នកស្រីបានឲ្យដឹងថា "កូនហ្នឹងកាលពីអាយុ៤ឆ្នាំ វានៅក្បែរចង្កៀង ហើយចង្កៀងផ្ទុះរលាកទៅ។ ដល់ពេលជា មាត់ហើយនិងកជាប់គ្នា"។ អ្នកស្រីញ៉ៅបានដឹងដំណឹងអំពីពេទ្យវះកាត់នេះដោយសារគ្រូពេទ្យបានចុះទៅដល់ផ្ទះគាត់ ហើយបានឃើញកូនប្រុសរបស់គាត់ ក៏បានណាត់មកវះកាត់តែម្តងទៅ។ អ្នកស្រីញ៉ៅ ជាអ្នកធ្វើស្រែចំការ រស់នៅក្នុងឃុំទ្រា ខេត្តតាកែវ បានបន្តថា នៅក្នុងមន្ទីរពេទ្យនេះអ្នកស្រី មិនចំណាយថ្លៃវះកាត់ ឬថ្នាំពេទ្យច្រើនដូចពេទ្យឯកជនទេ។ អ្នកស្រីញ៉ៅ "មកដល់គេឲ្យកូនជុះឈាម អស់១១០០០រៀល។ ថ្លៃសម្រាក ថ្លៃពេទ្យវះកាត់ អត់បង់ទេ តែទិញម្ហូបហូបខ្លួនឯង"។

មិនសូវខុសគ្នាពីអ្នកស្រី ផាន់ ញ៉ៅ ប៉ុន្មានទេ អ្នកដែលសម្រាកនៅក្នុងបន្ទប់ជាមួយគ្នានោះ ក៏បាននិយាយស្រដៀងគ្នាដែរ ហើយពួកគាត់ទាំងនោះហាក់ពេញចិត្ត នឹងមកព្យាបាលក្នុងមន្ទីរពេទ្យនេះណាស់។

អ្នកស្រីឃឹម សើន អាយុ៣២ឆ្នាំ កំពុងអង្គុយរង់ចាំការពិនិត្យផ្ទៃពោះកូនទី២របស់គាត់ ខណៈដែលគ្រូពេទ្យកំពុងប្រជុំនៅឡើយ។ នេះជាលើកទី១ហើយដែលអ្នកស្រី បានមកទទួលសេវាផ្ទៃពោះ ពីកម្មវិធីគាំពារមាតានិងទារករបស់មន្ទីរពេទ្យព្រះកុមារយេស៊ូ ដែលសហការជាមួយមន្ទីរពេទ្យបង្អែកខេត្តតាកែវ។ អ្នកស្រីបានឲ្យដឹងថា "ទើបដឹងតាមគេដែរហ្នឹង។ កូនបានប៉ុន្មានខែហើយ។ រាល់ដងទៅតែពេទ្យឯកជន ព្រោះអត់ដែលដឹងថានៅពេទ្យនេះមានផង។ ដឹងតែថាមានកន្លែងមើលកូនក្មេង"។ អ្នកស្រីបានបន្ថែមទៀតថា អ្នកស្រីធ្លាប់នាំកូនប្រុសរបស់គាត់ទៅព្យាបាល នៅប្រទេសអ៊ីតាលី តាមរយៈ មន្ទីរពេទ្យព្រះកុមារយេស៊ូនេះ។ អ្នកស្រី សើន "កូនកើតមកបានពីរ ឬបីខែបានដឹងថាបេះដូងចំហ ព្រោះចេះតែហត់ មកជួបពេទ្យគេថាអញ្ចឹង។ ក្រោយមកបានអាយុ៥ឆ្នាំ ទើបខាងមន្ទីរពេទ្យ(ព្រះកុមារយេស៊ូ) យកទៅព្យាបាលនៅអ៊ីតាលី"។

ការព្យាបាលនៅបរទេសនេះ អ្នកស្រីសើនបានឲ្យដឹងថា អ្នកស្រីមិនបានចំណាយអ្វីសោះឡើយ។ អ្នកស្រីសើន "ទៅអ៊ីតាលីអត់អស់អីទេ។ គេជួយទាំងអស់។ ទាំងហូប ស្នាក់នៅ ថ្លៃពេទ្យ ថ្លៃជិះ(យន្តហោះ)។ គេយកចិត្តទុកដាក់នឹងយើងណាស់។ បើអត់ពេទ្យស្រុកគេ ខ្ញុំគិតថា កូនខ្ញុំអត់ជានាទេ"។

សព្វថ្ងៃនេះកូនរបស់អ្នកស្រី ឃឹម សើនកំពុងរៀននៅសាលាបឋមសិក្សា ហើយរៀងរាល់៣ខែម្តង មន្ទីរពេទ្យព្រះកុមារយេស៊ូ បានបញ្ជូនកូនរបស់គាត់ទៅពិនិត្យ និងតាមដានជំងឺបេះដូងនៅមន្ទីរពេទ្យកាល់ម៉ែត។

លោកវេជ្ជបណ្ឌិតតែ វ៉ាន់ថា ជាប្រធានគ្រប់គ្រងកម្មវិធីផ្នែកកុមារនិងជាអនុប្រធាន មន្ទីរពេទ្យបង្អែកខេត្តតាកែវ បានមានប្រសាសន៍ថា ការជួយ និងការសហការរបស់មន្ទីរពេទ្យ ព្រះកុមារយេស៊ូ បានចូលរួមអភិវឌ្ឍផ្នែកសុខភាពរបស់កុមារកម្ពុជា យ៉ាងច្រើន ហើយក៏បានជួយកាត់បន្ថយ អត្រាស្លាប់របស់កុមារនិងទារកផងដែរ។

លោកវេជ្ជបណ្ឌិត តែ វ៉ាន់ថា "អ្វីដែលខ្ញុំចងចាំ នូវការសហការរវាងមន្ទីរពេទ្យតាកែវ និងមន្ទីរពេទ្យព្រះកុមារយេស៊ូគឺអគារថែទាំទារក (Neonatal) ព្រោះពីមុនមកការស្លាប់នៃទារកដែលកើតមក មានអត្រាខ្ពស់ ហើយបន្ទាប់ពី ការរៀបចំជួសជុលឡើងវិញ នៃមន្ទីរពេទ្យព្រះកុមារយេស៊ូមកគឺការស្លាប់របស់ទារកថយចុះ និង ដោយមានការបំពាក់ឧបករណ៍ និងអុកស៊ីសែនផ្សេងៗដែលជាជំនួយមួយដល់ការកាត់បន្ថយ ចំនួនស្លាប់ទារកនិងកុមារនៅកម្ពុជា។

លោកវេជ្ជបណ្ឌិតបន្ថែមថា ក្នុងស្ថិតិរបស់រដ្ឋាភិបាលឆ្នាំ២០០៥បានឲ្យដឹងថា អត្រាស្លាប់របស់ទារក និងកុមារមានចំនួន៣៧នាក់ក្នុងចំណោម ១០០០នាក់កើតរស់។ ហើយក្នុងឆ្នាំ ២០១០ មានអត្រាស្លាប់ទារក និងកុមារមាន២៧នាក់ ក្នុង១០០០នាក់កើតរស់។ ហើយចំនួននេះមានការថយចុះបន្តិចប៉ុណ្ណោះ ហេតុនេះទើបក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍផ្សេងចូលរួមទាំងអស់គ្នាដើម្បីចូលរួមកាត់បន្ថយការស្លាប់របស់ទារក និងកុមារ។

លោកប្រ៊ុយណូ ហ្គាវីអូលី (Bruno Gavioli) អ្នកទទួលខុសត្រូវមន្ទីរពេទ្យព្រះកុមារយេស៊ូបានមានប្រសាសន៍ថា មន្ទីរពេទ្យព្រះកុមារយេស៊ូ ជាមន្ទីរពេទ្យ ដែលគ្រប់គ្រងដោយ សន្តអាសនៈនៅបុរីវ៉ាទីកង់ ហើយត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៦ នៅខេត្តតាកែវ ដោយធ្វើការសហការនឹងមន្ទីរពេទ្យបង្អែក ខេត្តតាកែវ។ លោកបានបន្ថែមទៀតថា បច្ចុប្បន្នមន្ទីរពេទ្យមានកម្មវិធី៥ធំៗគឺ ផ្នែកជំងឺកុមារទូទៅ(Clinical) ផ្នែកជំងឺកុមារវះកាត់ (Surgery) មណ្ឌលស្ត្រីមានផ្ទៃពោះ (Prenancy Women) បន្ទប់ថែទាំទារក (Neonatal Care) និងផ្នែកជំងឺកុមារកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។

លោកប្រ៊ុយណូ បានឲ្យដឹងទៀតថា ការសហការនេះគឺយើងសុំឲ្យមានបុគ្គលិកពេទ្យរដ្ឋធ្វើការងារ ដូចជាវេជ្ជបណ្ឌិត គិលានុដ្ឋាកយិកាជាដើម។ ចំណែកខាង មន្ទីរពេទ្យព្រះកុមារយេស៊ូ គឺយើងផ្តល់ជាអាគារ ឧបករណ៍ ផ្តល់យោបល់ បណ្តុះបណ្តាលបុគ្គលិករដ្ឋ ដើម្បីឲ្យពួកគាត់ធ្វើការតាមទិសដៅរបស់យើង គឺគោរពសេចក្តីថ្លៃថ្នូររបស់អ្នកជំងឺ ជាពិសេសមិនឲ្យមានអំពើពុករលួយ ការបដិសេធមិនទទួលព្យាបាលអ្នកជំងឺ និងផ្តល់សេវាជាទីគាប់ចិត្តដល់ប្រជាជន និងអ្នកជំងឺ។ លោកបានបញ្ជាក់ថា "ប្រសិនបើពួកគាត់គោរពតាមអនុសារណៈរបស់មន្ទីរពេទ្យព្រះកុមារយេស៊ូ និងមន្ទីរពេទ្យបង្អែកខេត្តតាកែវ ពួកគាត់នឹងទទួលបានប្រាក់ឧបត្ថម្ភបន្ថែមពីមន្ទីរពេទ្យរបស់យើង"។

ក្នុងមួយឆ្នាំៗមន្ទីរពេទ្យព្រះកុមារយេស៊ូ បានទទួលកុមារនិងស្ត្រីមានផ្ទៃពោះជាច្រើនពាន់នាក់ ដើម្បីព្យាបាលនិងថែទាំសុខភាព។ ទិន្នន័យក្នុងឆ្នាំ២០១៤បានបង្ហាញថា ចំនួនកុមារក្នុងផ្នែកជំងឺទូទៅ និងវះកាត់ មានចំនួន ២៤៩៩នាក់ (៩៤៦ជាកុមារដែលក្រោយអាយុ៥ឆ្នាំ) ផ្នែកថែទាំមាតា(ស្ត្រីមានផ្ទៃពោះ) មានចំនួន ២៤៩នាក់ ផ្នែកថែទាំទារក (Neonatal Care) មានទារក៣២៥នាក់ និងផ្នែកអាហារូបត្ថម្ភកុមារមានចំនួន៥១នាក់ បានមកទទួលសេវាកម្មពីមន្ទីរពេទ្យកាតូលិកមួយនេះ។

លោកប្រ៊ុយណូ បានបន្ថែមថា នៅទីនេះកុមារគ្រប់គ្នាអាចមកទទួលសេវាពីមន្ទីរពេទ្យបាន។ យើងផ្តល់អាហារដល់អ្នកជម្ងឺ និងការស្នាក់នៅ នៅពេល អ្នកជំងឺចាំបាច់សម្រាក នៅមន្ទីរពេទ្យរបស់យើង។

នៅក្នុងឆ្នាំថ្មីនេះ លោកប្រ៊ុយណូ បានឲ្យដឹងថាលោកមានគម្រោងនឹងអភិវឌ្ឍបន្ទប់ថែទាំទារក ឲ្យកាន់តែប្រសើរឡើង ព្រោះពេលបច្ចុប្បន្ន អត្រានៃទារកកើតមិនគ្រប់ខែ មានចំនួនខ្ពស់។ ហើយសព្វថ្ងៃមន្ទីរពេទ្យព្រះកុមារយេស៊ូអាចទទួលកុមារកើតមិនគ្រប់ខែនេះបាន តែចំនួន៦នាក់ប៉ុណ្ណោះ៕

**ដោយកញ្ញា**

# ប៊ែរណា ឈឹម ឈុនសារ ( Bernard Chim Chunsar ) ជាបព្វជិតក្រុមបេណេឌិកតាំង



លោកឈឹម ឈុនសារ ជាជនជាតិខ្មែរ មានស្រុកកំណើតនៅខេត្តបាត់-ដំបង។ រៀនសូត្រនៅបាត់ដំបង។ ក្រោយមក ចូលរៀនបួសនៅផ្សារតូច (ភ្នំពេញ) ជាអនុទេវវិទ្យាល័យ។ ក្រោយមក លោកចាប់អារម្មណ៍ ជីវិតជាបព្វជិតបេណេឌិកតាំង ហើយលោកមករស់នៅក្រុងកែប ក្នុងអារាមអ្នកបួស។

លោកមានចិត្តសប្បុរស ជួយដឹកនាំធ្វើការងារក្នុងវត្តអារាម។ គាត់ណែនាំអ្នករៀបចំបួស និងអប់រំវិន័យរបស់ក្រុមសម្រាប់ពួកគេ នៅក្នុងអារាម។ លោកទទួលខុសត្រូវ ខាងកសិកម្មដែលធ្វើសម្រាប់បរិភោគ ក្នុងអារាម។

លោកឈុនសារមិនគិតប្រយោជន៍ផ្ទាល់ខ្លួន ដោយធ្វើដើម្បីព្រះជាម្ចាស់។ ទោះបី គាត់មកពីក្រុមគ្រួសារធូរធារក៏ដោយ។ ប៉ុន្តែ គាត់លះបង់ដើម្បីព្រះជាម្ចាស់។ គាត់ឆ្លើយសំណួរគ្រីស្តបរិស័ទម្នាក់ថា "ខ្ញុំចូលចិត្តធ្វើជាអ្នកបួស"។

លោកមានរបៀបនិយាយ ប្រកបដោយចំណេះដឹង ហើយលោកក៏មានទំនាក់ទំនង ដល់ចៅហ្វាយខេត្តផងដែរ។ ពេលមាន តម្រូវការផ្នែកទំនាក់ទំនងជាមួយរដ្ឋាភិបាល គឺលោកជាអ្នកចេញមុខ ដោយសារលោកជាខ្មែរ។ លោកទទួលការតែងតាំងជា បូជាចារ្យនៅថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ១៩៦៥។ លោកមានតួនាទីថ្វាយអភិបូជាសម្រាប់បងប្រុស។ លោកជាបូជាចារ្យខ្មែរដំបូង របស់ក្រុមគ្រួសារនេះ។

ចាប់ពីឆ្នាំ១៩៧០ទៅ ក្រុងកែបមានសង្គ្រាមខ្លាំង រវាងវៀតកុង និងខ្មែរក្រហម ច្បាំងជាមួយនឹង កម្ពុជាសាធារណរដ្ឋ។ ពេលនោះ លោករំឭកយើងថា "យើងមិនដឹង ទៅណាទៀតទេ មានតែសង្ឃឹមទៅលើព្រះជាម្ចាស់ និង អធិដ្ឋានតែប៉ុណ្ណឹង"។

ក្រោយមកឆ្នាំ១៩៧៣ ខ្មែរក្រហមយកក្រុងកែបបាន។ លោកដឹកនាំបព្វជិត២-៣រូបទៀត និងគ្រួសារកាតូលិកខ្លះទៅភ្នំពេញ។ លោកជួយទំនាក់ទំនង រហូតបានឡានមកដល់ភ្នំពេញ។ លោកដឹកនាំ នវកកាតូលិក (របស់វត្តអារាមគឺលោកជានីសេងនិមិត្ត និងអង់ទ្រេ រដ្ឋរំជួរ។ ពេលលោកទាំងបី មកដល់ភ្នំពេញលោកទៅរស់នៅ ក្នុងទេវវិទ្យាល័យធំនៅជ្រោយចង្វារ។

នៅពេលនោះ ក្រុមរបស់លោកមានឈ្មោះល្បី ព្រោះលោកបានជួយអ្នកក្រីក្រ និងលោកមានទំនាក់ទំនងជាមួយព្រះសង្ឃពុទ្ធសាសនាដែរ។

ពេលភ្នំពេញបែក ខ្មែរក្រហមជម្លៀសលោក និងនវកៈពីរអង្គទៀតរួមជាមួយលោកសាឡាស់ លោកសាឡឹម និងលោកចំរើនទៅភូមិតាំងគោក (ប្រវត្តិព្រះសហគមន៍កម្ពុជាភាសាអង់គ្លេស ទំព័រ ១៤៤) ជាមួយគ្រីស្តបរិស័ទ ដែលមកពីភូមិព្រះមា-តា។ លោកនិងនវកៈ២នាក់ ព្រមទាំងយុវជន៤នាក់ ស្នាក់នៅក្នុងខ្ទមតូចមួយ នៅភូមិសំរោង។ ក្រោយមកគេឲ្យពួកលោក នៅភូមិអណ្តូងដា។ នៅពេលនោះ លោកបានជួបគ្រីស្ត-បរិស័ទ ហើយលបណាត់គ្នា ដើម្បីថ្វាយអភិបូជា ដោយសម្ងាត់ ថ្វាយការអត់ឃ្លានទៅព្រះ បិតា។

ប្រហែល ខែកញ្ញា ឆ្នាំ ១៩៧៥ ក្រោយមក ដោយសារអត់ឃ្លានពេកលោកប៊ែរណា លោករំជួរ និងលោកនិមិត្ត ទៅថ្វាយអភិបូជាចុងក្រោយនៅតាំងគោកជាមួយលោកសាឡាស់សាឡឹម និងលោកចំរើន។ នៅពេលនោះលោកនិយាយថា "យើងត្រូវចែកផ្លូវគ្នាស្វែងរកកូនចៀម យើងមិនអាចនៅផ្តុំគ្នាមួយកន្លែងដូច្នេះទេ ... ។" ក្រោយមក លោកទាំងបីត្រូវខ្មែរក្រ-ហមចាប់ ហើយសម្លាប់នៅតាមផ្លូវត្រង់ភូមិជុំ (ប្រវត្តិព្រះសហគមន៍ភា-សាអង់គ្លេសទំព័រ ១៥៣)៕

## ព័ត៌មានកាតូលិកអន្តរជាតិ .

### វាទីកង់ស្នើឲ្យអង្គការសហប្រជាជាតិ ចាត់វិធានការការពារគ្រីស្តបរិស័ទនៅមជ្ឈិមបូព៌ា

យោងទៅតាមវិទ្យុវាទីកង់ បានឲ្យដឹងថា កាលពីថ្ងៃសុក្រសប្តាហ៍កន្លងទៅនេះ បុរីវាទីកង់បានប្រាប់ក្រុមប្រឹក្សា សន្តិសុខអង្គការសហប្រ-ជាជាតិថា គ្រីស្តសាសនានៅមជ្ឈិមបូព៌ា គឺកំពុងតែរងនូវការភ័យខ្លាច។

ប្រភពដដែល បានបន្តទៀតថាជុំវិញអំពើហិង្សា និងការគំរាមកំហែងមកលើគ្រីស្តបរិស័ទ នៅក្នុងតំបន់នោះ វាទីង់បានទាមទារឲ្យអង្គការសហប្រជាជាតិ ចាត់វិធានការណាមួយ ឲ្យប្រាកដប្រជាដើម្បីការពារគ្រីស្តសាសនា និងគ្រីស្តបរិស័ទ។

លោក បែណាតឌីតូ អូហ្សា អគ្គអភិបាល និងជាអ្នកអង្កេតការអចិន្ត្រៃយ៍ប្រចាំ នៅអង្គការសហប្រជាជាតិបានជំរុញឲ្យសហគមន៍អន្តរជាតិ ធ្វើនូវអ្វីៗដែលអាចនឹងបង្ការគ្រោះថ្នាក់ ពីការវាយប្រហារឬ រំលោភបំពានជាតិសាសន៍ឬដោយសាសនា។

លោកបានអះអាងថាគ្រីស្តបរិស័ទដែលកំពុងតែរស់នៅ តំបន់ភាគខាងជើងនៃប្រទេសអ៊ីរ៉ាក់ និងតំបន់ដែលកំពុងតែមានអំពើហិង្សា កំពុងតែរងគ្រោះធ្ងន់ធ្ងរបំផុត ដោយសារតែពួកគេត្រូវបង្ខំឲ្យចេញពីផ្ទះ សម្លាប់ រំលោភបំពានផ្លូវភេទ ។ល។

### សម្តេចប៉ាបជួបនិងលើកទឹកចិត្តទណ្ឌិត

វិទ្យុវាទីកង់ បានរាយការណ៍ថា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៥ បានធ្វើដំណើរទៅបំពេញទស្សនកិច្ច និងជួបអ្នកទោសនៅក្នុងទីក្រុងមួយ នៅភាគខាងត្បូងប្រទេសអ៊ីតាលី ។

ប្រភពដដែល បានរាយការណ៍ថា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានទៅទស្សកិច្ច និង សាកសួរសុខទុក្ខអ្នកទោស ហើយបាននិយាយថាព្រះជាម្ចាស់ គឺមិនមែនបោះបង់កូនចៅរបស់ព្រះអង្គណាម្នាក់ឡើយ ។

ប្រភពដដែលបានរាយការណ៍ថាពន្ធនាគារ ដែលសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានទៅសាកសួរសុខទុក្ខអ្នកទោស គឺពន្ធនាគារហ្គីស៊ីប៉ សាលរៀដែលស្ថិតនៅក្នុងផ្នែករដ្ឋបាលនៃទីក្រុងណេបួ្ល។

ប្រភពដដែល បានបន្តទៀតថា នៅក្នុងអំឡុងពេលនោះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ក៏បានសាកសួរសុខទុក្ខ និង បានទទួលទានអាហារថ្ងៃត្រង់រួមជាមួយអ្នកទោស ប្រមាណជា ១២០ រូប។

ប្រភពដដែល បានរាយការណ៍ថា នៅពេលដែលបានជួបសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បណ្តាអ្នកទោស គឺបានបង្ហាញនូវអារម្មណ៍កក់ក្តៅនិងមានក្តីសង្ឃឹមឡើងវិញ ទោះបីជាពួកគេកំពុងតែស្ថិតនៅក្នុងពេលទទួលទោសហើយក៏ដោយចុះ ៕



លោកបូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងសូដ៍

### ថ្ងៃអាទិត្យនៃបុណ្យចម្លង

៥០ ថ្ងៃខាងមុខនេះ គឺថ្ងៃអាទិត្យទាំង ៨ នៃបុណ្យចម្លង។ ព្រះសហគន៍ណែនាំឲ្យយើងរិះគិត នឹកស្មឹងស្មាធ៍អំពីព្រឹត្តិការណ៍ដ៏អស្ចារ្យ តែមួយ គឺព្រះបិតាបានប្រោសឲ្យព្យាការីយេស៊ូមានជីវិតថ្មី និងតែងតាំងលោកជាព្រះគ្រីស្ត និង ជាព្រះអម្ចាស់។ នេះជាស្នូលនៃជំនឿរបស់យើងជាគ្រីស្តបរិស័ទ។ ព្យាការីយេស៊ូមិនគ្រាន់តែ"រស់ឡើងវិញ" គឺរស់នៅដូចពីមុនប៉ុណ្ណោះទេ តែលោកទទួលឋានៈជាព្រះអម្ចាស់ ស្មើនឹងព្រះបិតា ហើយក៏ជាព្រះគ្រីស្តដែលរំដោះយើងឲ្យរួចពីសេចក្តីអាក្រក់នានា។ ព្រះអង្គចងសម្ពន្ធមេត្រីថ្មី ដោយប្រទានព្រះវិញ្ញាណ ដែលជាព្រះជន្មផ្ទាល់របស់ព្រះអង្គឲ្យអស់អ្នកដែលផ្ញើជីវិតលើព្រះអង្គ។ យើងពិបាកយល់អត្ថន័យព្រឹត្តិការណ៍នេះ។ ហេតុនេះលោកលូកាជាអ្នកអប់រំជំនឿដ៏ប្រសើរ ហើយក្រោយមកព្រះសហគមន៍បានបំបែកព្រឹត្តិការណ៍នេះ ហាក់ដូចជាព្រឹត្តិការណ៍បី គឺព្យាការីយេស៊ូដែលគេសម្លាប់យ៉ាងសែនអាម៉ាស បានទទួលជីវិតថ្មី (បុណ្យចម្លង ត្រូវជាថ្ងៃ៥ មេសា ) ព្រះបិតាបានលើកព្យាការីយេស៊ូ ឲ្យទៅជាព្រះគ្រីស្តនិងជាព្រះអម្ចាស់ (បុណ្យព្រះបិតាលើកព្រះយេស៊ូឡើង ត្រូវនឹងថ្ងៃទី ១៧ ឧសភា) ហើយព្រះបិតាចងសម្ពន្ធមេត្រីថ្មីដោយប្រទានព្រះវិញ្ញាណនិងធម្មវិន័យថ្មី (បុណ្យថ្ងៃទីហាសិបត្រូវជាថ្ងៃ ២៤ ឧសភា)។ ជំនឿនេះពិបាកពន្យល់យ៉ាងច្បាស់ ហេតុនេះបានជា អ្នកនិពន្ធគម្ពីរដំណឹងល្អ តែងតំណាលរឿងនិងប្រើនិមិត្តរូបជាច្រើនមកជួយឲ្យយើងរិះគិត។

### ៥ មេសា អាទិត្យទី១ នៃបុណ្យចម្លង (លក ២៤:១៣-២៥)

យើងកំពុង ធ្វើដំណើរក្នុងលោកនេះ ដូចសាវ័កពីរនាក់កំពុងធ្វើដំណើរទៅភូមិអេម៉ាអ៊ូស។ យើងតែងតែជួបប្រទះឧបសគ្គជាច្រើនដែលរារាំងមិនឲ្យបានសេចក្តីសុខ គឺយើងនៅតែជាអ្នកក្រ ជួនកាលយើងជួបបញ្ហាក្នុងក្រុមគ្រួសារ មានជម្ងឺ មានបងប្អូនសាច់ញាតិបាត់បង់ជីវិត ជួនកាលយើងជួបបរាជ័យក្នុងការងារ ប្រឡងធ្លាក់ មានអយុត្តិធម៌ក្នុងសង្គម មានសង្គ្រាមក្នុងប្រទេសជាច្រើន ។ល។ តើធ្វើដូចម្តេចឲ្យយើងជឿថា ព្រះយេស៊ូពិតជាព្រះអម្ចាស់ ដែលសង្គ្រោះយើងបាន? យើងក៏ដូចសាវ័កពីរនាក់ដែរ គឺសព្វថ្ងៃព្រះយេស៊ូធ្វើដំណើរជាមួយយើង តើយើងមិនអាចស្គាល់ព្រះអង្គបាន ព្រោះព្រះអង្គដែលមានព្រះជន្មថ្មីដ៏រុងរឿង លែងមានទ្រង់ទ្រាយដូចពីមុន ព្រះអង្គទាក់ទាញចិត្តយើងដោយព្រះវិញ្ញាណ។ នៅពេលយើងរួមគ្នាថ្វាយអភិបូជា យើងរិះគិតអំពីគម្ពីរ ទើបយើងអាចទទួលស្គាល់អត្ថន័យនៃទុក្ខរបស់ខ្លួន និងទុក្ខរបស់មនុស្សលោកបាន។ ក្នុងអភិបូជា យើងក៏រួមជាមួយព្រះយេស៊ូដែលបូជាព្រះជន្ម ទើបយើងអាចជឿថា ប្រសិនបើ យើងសុខចិត្តខាតប្រយោជន៍ផ្ទាល់ខ្លួន រហូតដល់បាត់បង់ជីវិតសម្រាប់អ្នកដទៃ យើងរួមជាមួយព្រះអង្គដែល មានព្រះជន្មថ្មីដ៏រុងរឿងមែន។ នេះជាជំនឿរបស់ព្រះសហគមន៍។

### ១២ មេសា អាទិត្យទី២ នៃបុណ្យចម្លង (យហ២០:១៩៣១)

ទាំងក្រុមសាវ័ក ទាំងលោកថូម៉ាសមិនស្គាល់ព្រះយេស៊ូ ដែលមានព្រះជន្មថ្មីដ៏រុងរឿងទេ ព្រោះព្រះអង្គមិនគ្រាន់តែរស់ឡើងវិញប៉ុណ្ណោះទេ តែព្រះអង្គ បានចូលក្នុងភពរបស់ព្រះបិតាប្រកបដោយសិរីរុងរឿងហើយ ។ យើងក៏ជួបជុំគ្នាថ្ងៃអាទិត្យ ដូចក្រុមសាវ័កដែរ។ យើងត្រូវផ្ញើជីវិតទាំងស្រុងលើព្រះអង្គ ដែលទាក់ទាញចិត្តយើង ទើបយើងអាចស្គាល់ព្រះអង្គទុកជា ព្រះអម្ចាស់របស់ខ្លួន និងអាចនាំសេចក្តីសុខសាន្ត ដល់មនុស្សលោក។ យើង អាចក៏សម្តែងព្រះហឫទ័យមេត្តា ករុណារបស់ព្រះបិតាចំពោះមនុស្សគ្រប់ៗរូប ទាំងចំពោះមនុស្សអាក្រក់ទាំង ចំពោះមនុស្សល្អដែរ។

### ១៩ មេសា អាទិត្យទី៣ នៃបុណ្យចម្លង (លក២៤:៣៥-៤៨)

ថ្ងៃអាទិត្យ ពេលយើងរួមគ្នាថ្វាយអភិបូជា ព្រះយេស៊ូដែលមានព្រះជន្មថ្មីដ៏រុងរឿងគង់ជាមួយយើងយ៉ាងពិតប្រាកដ តែយើងពិបាកទទួលស្គាល់វត្តមានរបស់ព្រះអង្គ។ ពេលយើងទទួលនំប៉័ងប្រសិទ្ធិយើងរួបរួមជាមួយព្រះយេស៊ូ ដែលបូជាព្រះជន្មថ្វាយព្រះបិតាដោយសេចក្តីស្រឡាញ់។ យើងធ្វើសាក្សីអំពីជ័យជម្នះ របស់ព្រះអង្គលុះត្រាតែយើងសុខចិត្ត អត់ទោសដល់អ្នកខិលខូច ដោយសម្តែងព្រះហឫទ័យស្រឡាញ់ របស់ព្រះបិតាដែលអត់ទោសឲ្យគេ តាមរយៈព្រះយេស៊ូដែលបូជាព្រះជន្ម។

### ២៦ មេសា អាទិត្យទី៤ នៃបុណ្យចម្លង (យហ១០:១១-១៨)

ធម្មតាក្នុងសង្គមមនុស្ស អ្នកកាន់អំណាចតែងតែជិះជាន់អស់អ្នកដែលស្ថិតនៅក្រោមអំណាចរបស់ខ្លួន ។ ផ្ទុយទៅវិញ ព្យាការីយេស៊ូ "សុខចិត្តស៊ូប្តូរជីវិត "សម្រាប់កូនចៅ។ យើងទាំងអស់គ្នាមានអំណាចមួយចំណែកក្នុងក្រុមគ្រួសារ និងក្នុងសង្គម។ តើយើងប្រើអំណាចរបស់ខ្លួនយ៉ាងណា? ប្រសិនបើយើងស្មគ្រកក្តីចំពោះស្វាមីភរិយា គោរពគាត់ ស៊ូប្តូរជីវិតសម្រាប់កូន និងសម្រាប់អ្នកជិតខាង យើងបានដូចព្រះយេស៊ូ។ យើងមិនបាច់ធ្វើការអស្ចារ្យទេ តែត្រូវស្រឡាញ់គេ ដោយមានបំណងចង់ឲ្យគេចម្រើនឡើង ទើបយើងស៊ូប្តូរជីវិតដូចព្រះអង្គ៕

---

## កំណាព្យ

## ក្នុងគ្រួសារត្រូវចេះបម្រើគ្នាទៅវិញទៅមក ( បទពាក្យ ៧ )

១- សុភមង្គលឋិតត្រង់ណា
មើលតែបំណាំរាល់វេលា
បើក្នុងគ្រួសារមិនជួយគ្នា
រើសអើងការងាររៀងៗខ្លួន។

២- ឃើញការស្ត្រីស្តីប្រដែង
សម្អាតចានឆ្នាំងបាំងថៃធូន
នេះការងារឯងថ្លែងផ្ទួនៗ
រៀបចំសមសួនផ្ទះសម្បែង។

៣- ថៃកូនស្រីប្រុសជុសសម្អាត
មើលការខុសត្រូវផ្ទះខ្លួនឯង
ទុកដាក់ត្រូវខ្នាតគ្រប់កន្លែង
ធាតុពិតដាក់ស្តែងឯងជាស្រី។

៤- បើឃើញភរិយាជាប់រវល់
ជួយទុក្ខធុរៈភរិយាស្រី
គួរណាស់មកដល់លោកស្វាមី
ការងាររួមដៃឆាប់រួចរាល់។

៥- បើអង្គុយចាំដាំស្លរឆ្អិន
ទើសនេះទើសនោះដោយអំពល់
រអ៊ូពោលកិនមិនចេះទាល់
រករឿងខឹងដល់ឈ្លោះឲ្យបាន។

៦- អាងខ្លួនធ្វើការហេវហត់ខ្លាំង
ចំអិនអាហារយូរខកខាន
មកអស់កម្លាំងពេញទាំងប្រាណ
ថ្មើរណាទើបបានស៊ីចុកទៅ។

៧- ប្រសិនភរិយាទ្រាំសំដី
បញ្ជួសបន្សោកបោកបោះទៅ
ដែលលោកស្វាមីពោលសំដៅ
សង្កត់ចិត្តស្ងៀមនៅមិនឆ្លើយ។

៨- តែបើចិត្តខឹងនឹងស្វាមី
ហត់នឹងការផ្ទះមិនទាន់ហើយ
ត្រគោះសំដីឥតកោះត្រើយ
តបវិញបណ្តោយឲ្យចាញ់ឈ្នះ។

៩- ជំលោះផ្ទុះឡើងដោយសារអ្វី
មិនចេះសម្រួលដល់គ្នាខ្លះ
ឈ្លោះប្រពន្ធប្តីស្រែកពេញផ្ទះ
របស់ក្នុងផ្ទះបោកខ្ទេចខ្ទី។

១០- សុភមង្គលក្នុងគ្រួសារ
ជួយបំរើគ្នាដោយអញ្ជលី
ឋិតនៅត្រង់ថាអ្នកទាំងពីរ
ស្មោះរួមជីវិតទាំងពីរកាយ។

១១- ទើបក្នុងគ្រួសារមានក្តីសុខ
សុភមង្គលរីកស្រស់ស្រាយ
គ្មានរឿងកើតទុក្ខក្តៅក្រហាយ
ស្គាល់តែសប្បាយក្នុងជីវិត។

និពន្ធដោយ: អ្នកស្រី ខុខ ណាទី

# រូបថតសកម្មភាពព្រះសហគមន៍ទាំងបីភូមិភាគ



គ្រីស្តបរិស័ទនៅកំពុងចាមក្រុងធ្វើពិធីហែស្លឹកកាលពីថ្ងៃទី២៩ មីនា។



រូបជុំគ្នារបស់លោកអភិបាលអូលីវីយេនិងគ្រីស្តបរិស័ទនៅជប៉ុន។



លោកអភិបាលចូលរួមជាអធិបតីក្នុងពិធីរំឭកខួបពីរឆ្នាំនៃការស្រង់រូបសំណាកព្រះមាតានៃទន្លេមេគង្គ។



លោកអភិបាលអូលីវីយេជូនកុំព្យូទ័រចំនួន១០គ្រឿង ទៅរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា។



ទិវាយល់ដឹងពីគ្រាប់មីននៅប៉ៃលិន (ចូលរួមពីសិស្សមណ្ឌលអារ៉ូពេ)។



បុណ្យហែស្លឹកនៅព្រះសហគមន៍បាត់ដំបង។


អេម៉ាណូអែល
"សម្លេងពីព្រះសហគមន៍កាតូលិក"

| | |
|---|---|
| ភ្នំពេញ | : **FM 104 Mhz** ម៉ោង ៥:០០-៦:០០ រាល់ថ្ងៃ |
| បាត់ដំបង | : **FM 91.0 Mhz** ម៉ោង ៧:៣០-៨:៣០ រាល់ថ្ងៃ |
| សៀមរាប | : **FM 107.5 Mhz** ម៉ោង ៧:០០-៨:០០យប់ រាល់ថ្ងៃ |
| កំពង់ធំ | : **FM 103.5 Mhz** ម៉ោង ៧:០០-៨:០០យប់ រាល់ថ្ងៃ |
| កំពង់ចាម | : **FM 100.5 Mhz** ម៉ោង ៧:០០-៨:០០ រាល់ថ្ងៃ |
| ព្រះសីហនុ | : **FM 92.5 Mhz** ម៉ោង ៥:០០-៦:០០ រាល់ថ្ងៃ |
| កំពត | : **FM 93.25 Mhz** ម៉ោង ៥:០០-៦:០០ រាល់ថ្ងៃ |

កម្មវិធីវិទ្យុ
**" ខ្ញុំត្រូវការអ្នក "**
ជាកម្មវិធីសម្រាប់យុវជន
ផ្សាយតាមរលកធាតុអាកាស FM99.5Mhz
រាល់ថ្ងៃអង្គារ៍
វេលាម៉ោង ១០:០០ - ១១:០០ព្រឹក